**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការលែងលះនៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **អុន ផល្លីន**

កញ្ញា **ពុទ្ធ លីនថាវី**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ម៉ូយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលរៀន ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទ **អុន ផល្លីន** និងនាងខ្ញុំ **ពុទ្ធ លីនថាវី** ជានិស្សិតជំនាន់ទី ១៩ ផ្នែក**នីតិសាស្ត្រ** ដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានកិត្តិយសសូមគោរពសម្តែងនូវកតញ្ញូតាធម៌ និង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ៖

លោកអ្នកមានគុណទាំងពីរ(**ឪពុក ម្តាយ**) ដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ ផ្គត់ផ្គង់ទំនុកបម្រុងសព្វគ្រប់បែបយ៉ាង រូបកូនមានថ្ងៃនេះគឺដោយសារលោកអ្នកមានគុណទាំងពីរ ដូច្នេះកូននឹងបោះជំហានទៅមុខបន្ថែមទៀត តាមរយៈការសិក្សាស្រាវជ្រាវដែលជាប្រទីបនាំកូនឈានទៅរកភាពជោគជ័យនៅក្នុងជីវិត។

ថ្នាក់ដឹកនាំប្រទេសជាពិសេសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលលោកបានខិតខំយកចិត្តទុកដាក់ពង្រឹងលើវិស័យអប់រំនៅកម្ពុជា។

លោកឯកឧត្តមសាកលវិទ្យាធិការ **លុយ ចណ្ណា** ព្រមទាំង**សាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំការងារ អប់រំ បណ្តុះបណ្តាល និង គ្រប់គ្រងរដ្ឋបាលនៅក្នុងសាកលវិទ្យាល័យនេះឲ្យមានដំណើរការកាន់តែប្រសើរឡើង និងរីកចម្រើនជាបន្តបន្ទាប់។

លោកស្រីសាស្ត្រាចារ្យ **ប៊ួយ ធីតា** បានជួយណែនាំ និងផ្តល់ជាយោបល់ល្អៗក្នុងការដឹកនាំការស្រាវជ្រាវលើប្រធានបទមួយនេះឡើងអោយសម្រេច គឺពិតជាអរគុណខ្លាំងណាស់នូវទឹកចិត្តលោកស្រីសាស្ត្រាចារ្យដែលតែងតែជួយជម្រុញ និងលើកជាកម្លាំងចិត្តដល់យើងខ្ញុំដែលជានិស្សិតដែលធ្វើការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សា ។

**បងប្អូន អ៊ំពូមីង** ដែលនៅស្រុកកំណើតយើងខ្ញុំដែលតែងតែសួរនាំ និងឲ្យជាកម្លាំងចិត្ត និងជាពិសេសមិត្តភក្តិ ប្រុស ស្រី ដែលបានសិក្សាជាមួយគ្នាកន្លងមក មានទាំងការពិភាក្សា ការណែនាំ ផ្តល់យោបល់ឲ្យគ្នាទៅវិញទៅមក រួមសុខទុក្ខនៃគ្រាសិក្សាជាមួយគ្នា ហើយក៏ជាអ្នកផ្តល់កម្លាំងចិត្តធំផងដែរ។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពនូវការដឹងគុណ និងសូមជូនពរអ្នកទាំងអស់ដែលបានរៀបរាប់ខាងលើនេះសូមឲ្យជួបប្រទះតែពុទ្ធពរទាំង ៥ ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភានៈ** និងប្រកបដោយភាពជោគជ័យរាល់ភារកិច្ចកុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

បន្ទាប់ពីទទួលបាននូវការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេលជិត ៤ឆ្នាំ យើងខ្ញុំដែលជានិស្សិតមានបំណងចង់សរសេរ និងចងក្រងសារណាអំពីប្រធានបទ **ការលែងលះនៅកម្ពុជាបច្ចុប្បន្ន** នេះដើម្បីបញ្ចប់ឆ្នាំសិក្សា។ ដោយផ្អែកលើចំណេះដឹងដែលទទួលបានតាមរយៈការសិក្សា ដោយផ្អែកទៅលើផ្នែកទ្រឹស្តី និងផ្អែកលើគោលបំណងដែលចង់ធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៅលើក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីដែលចូលជាធរមានផងដែរ។

ចំពោះការស្រាវជ្រាវទៅលើប្រធានបទសារណាមួយនេះ គឺយើងខ្ញុំបានខិតខំយកចិត្តទុកដាក់ស្រាវជ្រាវនូវរាល់ឯកសារដែលពាក់ព័ន្ធមកធ្វើការចងក្រងជាសៀវភៅដូចជា ច្បាប់ បទដ្ឋានគតិយុត្ត សៀវភៅសាស្ត្រាចារ្យ កម្រងមេរៀនរបស់មេធាវី ឯកសារស្រាវជ្រាវរបស់ក្រឡាបញ្ជី សៀវភៅសារណារៀមច្បង វេបសាយ និងសេចក្តីកំណត់មាត្រាច្បាប់ដែលដែលពាក់ព័ន្ធមកធ្វើជាមូលដ្ឋាននៃការស្រាវជ្រាវ។ ម្យ៉ាងទៀតការស្រាវជ្រាវមួយនេះក៏មានការណែនាំពីសាស្ត្រាចារ្យបង្គោលនៃសាកលវិទ្យាល័យនេះផងដែរ។ ខ្ញុំសង្ឃឹមថាការសិក្សាស្រាវជ្រាវមួយនេះ នឹងចូលរួមចំណែកផ្តល់ជាចំណេះដឹង ជាស្មារតីសម្រាប់និស្សិត និងអ្នកសិក្សាស្រាវជ្រាវស្វែងយល់ពីប្រធានបទមួយនេះ។ តាមរយៈការស្រាវជ្រាវប្រធានបទសារណាមួយនេះ យើងសង្កេតឃើញថាឯកសារជំនួយស្មារតីពាក់ព័ន្ធប្រធានបទមួយនេះ ហាក់បីដូចជាមិនទាន់គ្រប់គ្រាន់នៅឡើយទេ ហើយយើងខ្ញុំមិនហ៊ានថាការស្រាវជ្រាវមួយនេះមានភាពល្អឥតខ្ចោះមួយរយភាគរយនោះដែរ។

ហេតុនេះយើងខ្ញុំសូមទទួលការរិះគន់ទាំងឡាយណា ក្នុងន័យជួយស្ថាបនានូវកិច្ចការស្រាវជ្រាវមួយនេះឲ្យកាន់តែល្អប្រសើរឡើងថែមទៀត។ម្យ៉ាងទៀតក៏សូមអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងដែលកើតឡើងទាំងផ្នែក បច្ចេកទេស និងខ្លឹមសារ ពាក្យពេចន៍មួយចំនួនមានភាពខ្វះចន្លោះដោយអចេតនាណាមួយនៃការស្រាវជ្រាវមួយនេះផងដែរ។

ដូច្នេះរាល់ការស្រាវជ្រាវគឺតែងតែមានមានចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានមួយចំនួនដែលជាការផ្តាំផ្តួងកើតមានផងដែរ។ ដូចនេះហើយយើងខ្ញុំសូមឲ្យបងប្អូនមិត្តនិស្សិតក៏ដូចជាមិត្តអ្នកអាន សាស្ត្រាចារ្យទាំងអស់ សូមមេត្តាជួយកែតម្រូវ និងបំពេញចំណុចខ្វះខាត និងកំហុសឆ្គងដោយអចេតនារបស់យើងខ្ញុំដោយក្តីអនុគ្រោះ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម**........................................................................................................ ១

## ជំពូកទី១
## សញ្ញាណនៃការលែងលះ

**១.១. និយមន័យនៃការលែងលះ** .................................................................................៤

**១.២. លក្ខខណ្ឌដែលអាចលែងលះបាន**...........................................................................៥

**១.៣. មូលហេតុនៃការលែងលះចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧** .........................៦

១.៣.១. ករណីបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ..........................................................៦

១.៣.២. ករណីបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ................................៦

១.៣.៣. ករណីមិនបានដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង ០១ឆ្នាំ.......... ៧

១.៣.៤. ករណីសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ឆ្នាំ ផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍..........................................................................................៨

១.៣.៥. ករណីផ្សេងៗទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន...........................................................................................៨

**១.៤. ប្រភេទនៃការលែងលះ**..........................................................................................៩

១.៤.១ ការលែងលះដោយការព្រមព្រៀង .............................................................................៩

១.៤.២. ការលែងលះដោយគ្មានការព្រមព្រៀង.......................................................................៩

## ជំពូកទី២
## នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

**២.១. កិច្ចព្រមព្រៀងលែងលះ** ........................................................................................ ១១

**២.២. ពាក្យសុំលែងលះ**......................................................................................................១២

២.២.១.ពាក្យសុំជាលាយលក្ខណ៍អក្សរ....................................................................................១២

២.២.២. ពាក្យសុំដោយផ្ទាល់មាត់........................................................................................ ១៣

**២.៣. សមត្ថកិច្ចដោះស្រាយ**...............................................................................................១៤

២.៣.១. ក្រុមប្រឹក្សាឃុំ សង្កាត់ ............ ១៤
២.៣.២. សាលាដំបូងរាជធានី-ខេត្ត ............ ១៤
២.៣.២.១. ការពិនិត្យពាក្យសុំ ............ ១៥
២.៣.២.២. ការកោះហៅគូភាគី ............ ១៥
២.៣.២.៣. ការផ្សះផ្សានៅតុលាការ ............ ១៦
២.៣.២.៤. ការទាញហេតុផលដោយផ្ទាល់មាត់ និងការសាកសួរដោយឆន្ទានុសិទ្ធិ ............ ១៦
**២.៤. ការចេញដីកាសម្រេច** ............ ១៧
**២.៥. អានុភាពនៃការលែងលះដោយការព្រមព្រៀង** ............ ១៩
**២.៥.១. អានុភាពលើទ្រព្យសម្បត្តិ និងកាតព្វកិច្ច** ............ ១៩
២.៥.១.១ អានុភាពលើទ្រព្យសម្បត្តិ ............ ១៩
២.៥.១.២ អានុភាពលើកាតព្វកិច្ច ............ ២០
**២.៥.២. អានុភាពលើស្ថានភាពគ្រួសារ** ............ ២១
២.៥.២.១ ការកំណត់អ្នកមានអំណាចមេបា ............ ២១
២.៥.២.២ អានុភាពនៃអត្ថាធិនភាពនៅតែមាន ............ ២១
២.៥.២.៣ ការបញ្ចប់ទំនាក់ទំនងញាតិពន្ធ ............ ២១
២.៥.២.៤ ការបញ្ចប់ ឬ ការប្រែប្រួលនូវការប្រើនាមត្រកូលរបស់សហព័ទ្ធ ............ ២១

## ជំពូកទី៣
## នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង

**៣.១. នីតិវិធីនៃបណ្តឹងលែងលះ** ............ ២៣
**៣.១.១ ការផ្តើមនៃបណ្តឹងលែងលះ** ............ ២៣
៣.១.១.១ ការសរសេរពាក្យបណ្តឹងលែងលះ ............ ២៣
៣.១.១.២ កន្លែងទទួលពាក្យបណ្តឹង ............ ២៤
**៣.១.២ ការផ្សះផ្សា** ............ ២៥
៣.១.២.១ ការផ្សះផ្សានៅថ្នាក់ឃុំ សង្កាត់ ............ ២៥
៣.១.២.២ ការផ្សះផ្សាដោយតុលាការ ............ ២៥

៣.១.២.៣. ការហាមឃាត់ការផ្សះផ្សាក្នុងករណីអំពើហិង្សាក្នុងគ្រួសារធ្ងន់ធ្ងរ................ ២៦
**៣.១.៣ ការចាត់ចែងរក្សាការពារ** ........................................................................ ២៦
៣.១.៣.១ វិធានការឱ្យសហព័ទ្ធត្រូវតែរស់នៅបែកគ្នា ........................................... ២៧
៣.១.៣.២ វិធានការឱ្យមានការថែរក្សាកូនបណ្ដោះអាសន្ន........................................... ២៨
៣.១.៣.៣ វិធានការស្ដីពីការថែរក្សាទ្រព្យសម្បត្តិជាបណ្ដោះអាសន្ន ............................ ២៩
៣.១.៣.៤ វិធានការផ្ដល់ការផ្គត់ផ្គង់ហិរញ្ញវត្ថុបណ្ដោះអាសន្ន........................................ ២៩
៣.១.៣.៥ ធ្វើការរឹបអូសជាបណ្ដោះអាសន្ន.................................................................. ៣០
**៣.២.នីតិវិធីនៃការជម្រះក្ដី** ................................................................................... ៣០
៣.២.១ ការពិនិត្យលើពាក្យបណ្ដឹង ............................................................................ ៣០
៣.២.២ ការបញ្ជូនពាក្យបណ្ដឹងទៅចុងចម្លើយ ............................................................ ៣០
៣.២.៣ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផលលើកដំបូង...................... ៣១
៣.២.៤ ការលើកពាក្យបណ្ដឹងចោល ........................................................................... ៣១
៣.២.៥ ការបន្ថែម ឬការផ្លាស់ប្ដូរកម្មវត្ថុនៃបណ្ដឹង............................................................ ៣១
៣.២.៦ ការប្ដឹងតបរបស់ចុងចម្លើយ........................................................................... ៣១
៣.២.៧  ការស៊ើបអង្កេតរបស់ចៅក្រម និងការជម្រះក្ដី.................................................. ៣២
៣.២.៧.១.ដំណើរការទាញហេតុផលផ្ទាល់មាត់ ..........................................................៣៣
៣.២.៧.២. ឯកសារត្រៀម.......................................................................................... ៣៤
៣.២.៧.៣. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ................................................... ៣៥
៣.២.៧.៤. ការទាញហេតុផលដោយផ្ទាល់មាត់ .......................................................... ៣៦
**៣.៣. ការសម្រេចសេចក្ដី**............................................................................................ ៣៩
៣.៣.១ ខ្លឹមសារនៃសាលក្រម ................................................................................... ៣៩
៣.៣.២ ការសម្រេចមិនឱ្យលែងលះគ្នា ........................................................................ ៤០
៣.៣.៣ ការចូលជាស្ថាពររបស់សាលក្រម..................................................................... ៤០
**៣.៤ អានុភាពនៃការលែងលះដោយគ្មានការព្រមព្រៀង**........................................... ៤១
**៣.៤.១ អានុភាពចំពោះទ្រព្យសម្បត្តិ និងភាតព្វកិច្ច** ................................................. ៤១

**៣.៤.១.១ អានុភាពចំពោះទ្រព្យសម្បត្តិ** ........ ៤១

ក. ទ្រព្យសម្បត្តិអកម្ម (បំណុល) ........ ៤១

ខ. ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា ........ ៤២

គ. ទ្រព្យសម្បត្តិរបស់សហព័ទ្ធកំណត់ដោយច្បាប់ ........ ៤៣

**៣.៤.១.២ អានុភាពលើកាតព្វកិច្ច** ........ ៤៤

ក. ការបញ្ចប់កាតព្វកិច្ចរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅក្នុងចំណងអាពាហ៍ពិពាហ៍ ........ ៤៤

ខ. កាតព្វកិច្ចសងជំងឺចិត្តអាចកើតមាន ........ ៤៤

គ. កាតព្វកិច្ចបង់អាហារកិច្ច ........ ៤៤

**៣.៤.២. អានុភាពលើស្ថានភាពគ្រួសារ** ........ ៤៥

៣.៤.២.១ ការបញ្ចប់ទំនាក់ទំនងញាតិពន្ធ ........ ៤៥

៣.៤.២.២. ការបញ្ចប់ភាពជាសន្តតិជន ........ ៤៥

៣.៤.២.៣ នាមត្រកូលអាចត្រូវបានបញ្ចប់ដោយការលែងលះ ........ ៤៥

៣.៤.២.៤ អ្នកមានអំណាចមេបា ........ ៤៥

៣.៤.២.៥ អានុភាពនៃអត្តាធីនភាពនៅតែមាន ........ ៤៦

**សេចក្ដីសន្និដ្ឋាន** ........ ៤៧

**អនុសាសន៍** ........ ៤៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

សង្គមគ្រួសារ គឺជាកោសិកានៃសង្គម។ មនុស្សនៅក្នុងសង្គមជាតិមួយរមែងតែងមានគូគាប់ ហើយបង្កើតបានជាគ្រួសារដែលជាក្រិតក្រមនៃច្បាប់ធម្មជាតិ។ ហើយគ្រួសារនីមួយៗបង្កើតឡើងតាមរយៈអាពាហ៍ពិពាហ៍ដោយគោរពទៅតាមលក្ខខណ្ឌគតិយុត្ត និង តាមលក្ខណៈប្រពៃណី។ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាពិសេសមួយដែលខុសពីកិច្ចសន្យាធម្មតា។ ចំពោះកិច្ចសន្យាធម្មតាឲ្យតែសំណើរ និងស្ទីការត្រូវគ្នាគឺ កិច្ចសន្យាត្រូវបានបង្កើតឡើង ដោយលាយលក្ខណ៍អក្សរ ឬមិនធ្វើជាលាយលក្ខណ៍អក្សរក៏ដោយ ចំណែកឯកិច្ចសន្យាអាពាហ៍ពិពាហ៍វិញគឺ ត្រូវធ្វើដោយត្រូវអនុវត្តទៅតាមនីតិវិធីដែលមានកំណត់នៅក្នុងច្បាប់ជាធរមាន ចំពោះបុរស និងនារីណាដែលជាគូនឹងគ្នាដែលមានបំណងរួមរស់នៅជាមួយគ្នាជាគូអនាគត ហើយគិតថាមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នាត្រូវគោរពលក្ខខណ្ឌគតិយុត្តបង្កើតអាពាហ៍ពិពាហ៍។ មានន័យថាត្រូវគោរពលក្ខខណ្ឌ២នៃអាពាហ៍ពិពាហ៍គឺ លក្ខខណ្ឌគ្រឹះ (អាយុ ភេទ ភាពនៅលីវ ឆន្ទៈព្រមព្រៀង និងការហាមឃាត់អាពាហ៍ពិពាហ៍) និងលក្ខខណ្ឌទម្រង់(ការដាក់ពាក្យសុំច្បាប់អាពាហ៍ពិពាហ៍ ការបិទផ្សាយជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍)។ ដូច្នេះដើម្បីអោយអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់គឺ ត្រូវគោរពលក្ខខណ្ឌទាំងពីរខាងលើនេះទើបអាពាហ៍ពិពាហ៍អាចមានសុពលភាព ហើយបើអាពាហ៍ពិពាហ៍រវាងប្តី និងប្រពន្ធនោះត្រឹមត្រូវតាមច្បាប់ហើយ ដូចនេះការរំលាយចំណងអាពាហ៍ពិពាហ៍ក៏មិនអាចធ្វើតាមទំនើងចិត្តបានឡើយគឺ ត្រូវធ្វើតាមផ្លូវតុលាការ។ ផ្ទុយមកវិញបើសិនជាចំណងអាពាហ៍ពិពាហ៍ដែលបុរស-នារី បានរួមរស់នៅជាមួយគ្នាដោយគ្រាន់តែរៀបអាពាហ៍ពិពាហ៍ តាមបែបប្រពៃណីទំនៀមទំលាប់ ឬពិធីសាសនា ដោយមិនបានបំពេញលក្ខខណ្ឌដែលច្បាប់បានបញ្ញត្តិនោះទេគេហៅប្តីប្រពន្ធនោះថាជា ***អនីតិសង្វាស*** ហើយការរស់នៅជាអនីតិសង្វាសបែបនេះ ប្រសិនបើ បុរស-នារី រូបនោះអស់មនោសញ្ចេតនាលែងចង់រួមរស់នៅជាមួយគ្នាទៀត ពួកគេគ្រាន់តែសម្រេចចិត្តដើរចេញ បែកលំនៅឋានគ្នា និងលែងរួមរស់នៅជាមួយគ្នាជាការស្រេច។

ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ចំពោះការកសាងគ្រួសារដែលបង្កើតឡើងដោយអាពាហ៍ពិពាហ៍គឺកើតមានជាហូរហែរ។ ជាការពិតណាស់ប្តី ប្រពន្ធដែលក្នុងន័យច្បាប់គឺ សហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នារមែងតែងចង់បានសុភមង្គល កើតការវាលគុម្ពត្រជាក់ត្រជុំក្នុងគ្រួសារដែលសហព័ទ្ធទាំងឡាយប្រាថ្នាចង់បាន។ គ្រួសារមួយដែលរស់នៅបានសុខសាន្តថ្កាន គឺអាស្រ័យលើសហព័ទ្ធទាំងពីរចេះបង្កើតនូវសុភមង្គលផ្ទាល់ តាមរយៈការចេះស្រឡាញ់គ្នាទៅវិញទៅ

មក ចេះយកចិត្តទុកដាក់នឹងគ្នា ចេះថ្នាក់ថ្នម ការចេះអធ្យាស្រ័យឲ្យគ្នា ការជួយទំនុកបម្រុង ការរួម សុខទុក្ខនឹងគ្នាកត្តាទាំងនេះហើយដែលនាំឲ្យគ្រួសារកើតមានសុភមង្គល។ ដោយឡែកនៅក្នុង ក្រុមគ្រួសារខ្លះតែងកើតមានបញ្ហាមួយចំនួនដូចជា ការឈ្លោះទាស់ទែងពាក្យសំដី កាយវិការណាមួយ មិនសមរម្យពីសំណាក់សហព័ទ្ធ(ប្តី/ប្រពន្ធ) ដូចពាក្យចាស់តែងពោលថា ចានក្នុងរាវវាតែងតែប៉ះទង្គិច គ្នាវាជារឿងទូទៅដែលគ្រួសារតែងជួបប្រទះ។ ប៉ុន្តែបើការកើតមានបញ្ហានោះឈានទៅដល់ការកើត មានអំពើហិង្សាក្នុងគ្រួសាររវាងសហព័ទ្ធម្ខាងទៅលើសហព័ទ្ធម្ខាងទៀតវាជារឿងមួយនៃក្តីបារម្ភ។ អំពើហិង្សាក្នុងគ្រួសារគឺ ជាអំពើមួយដែលច្បាប់បានហាមឃាត់ចំពោះជនណាដែលបានប្រព្រឹត្ត ហើយមានទោសទណ្ឌថែមទៀត[1]។ អំពើហិង្សាក្នុងគ្រួសារជាកត្តាមួយផ្នែកដែលជំរុញអោយកើតមាន ឡើងនូវការលែងលះនៅក្នុងគ្រួសារ ម៉្យាងទៀតចំពោះសកម្មភាពនៃការប្រើអំពើហិង្សាដូចជា ការវាយ ដំយោរយៅ ការធ្វើទុកបុកម្នេញ ឬ ការធ្វើអំពើណាមួយនាំឲ្យគ្រោះថ្នាក់ខ្លាំងអាចប៉ះពាល់ដល់អាយុ ជីវិត ទៅលើសហព័ទ្ធម្ខាងនៃជនរងគ្រោះ ដែលជាហេតុធ្វើឲ្យសហព័ទ្ធម្ខាងនៃជនរងគ្រោះទ្រាំ លែងបាន និងអស់មនោសញ្ចេតនានឹងគ្នាតទៅទៀតនាំឲ្យឈានទៅដល់ការលែងលះ។ នេះជា មូលហេតុមួយផងដែរ នៅមានមូលហេតុផ្សេងទៀតដែលនាំឲ្យមានការលែងលះ។ ដូចម្តេចដែល ហៅថាការលែងលះ? តើការលែងលះអាចបណ្តាលមកមូលហេតុណាខ្លះ? តើសមត្ថកិច្ចណា ដែលអាចដោះស្រាយរឿងក្តីលែងលះបាន? តើនីតិវិធីបែបណា និងចំណាត់ការបែបណានៅក្នុង រឿងក្តីលែងលះ? តើអានុភាពនៃសាលក្រម និង ដីកាសម្រេចលែងលះយ៉ាងដូចម្តេចដែរ?

ការលើកយកប្រធានបទនេះមកសរសេរក្នុងគោលបំណងដូចតទៅ៖ (១)ចង់ឲ្យប្រជាពលរដ្ឋ យល់ដឹងអំពីច្បាប់ស្តីពីការលែងលះនេះ នៅពេលដែលពួកគាត់ចាប់កាន់សៀវភៅសារណានេះមក អាន វាជាការល្អដែលប្រសិនបើពួកគាត់យល់ដឹងអំពីច្បាប់នេះ នៅពេលដែលពួកគាត់យល់ពួកគាត់ មិនចង់ឲ្យកើតមានបញ្ហានៃការលែងលះនេះដែរ ពីព្រោះនីតិវិធីនៃការលែងលះមានលក្ខណៈស្មុគ ស្មាញ ហើយត្រូវឡើងតុលាការទៀត ដូច្នេះពួកគាត់នឹងខិតខំបង្កើតសុភមង្គលនៅក្នុងគ្រួសារ។ លើសពីនេះទៅទៀត ប្រសិនបើពួកគាត់ចង់ធ្វើការលែងលះពួកគាត់ងាយស្រួលហើយនឹងយល់ ច្បាស់ថាតើត្រូវធ្វើបែបណា និងដឹងថាតុលាការណាមានសមត្ថកិច្ចដែលត្រូវដោះស្រាយ។(២)គឺ ចង្អុលប្រាប់ចំណុចដែលពាក់ព័ន្ធនៃអាពាហ៍ពិពាហ៍នៅក្នុងដំណើរការនៃការលែងលះ នៅក្រោយ ពេលលែងលះតើមានផលវិជ្ជមាន និងផលអវិជ្ជមានអ្វីខ្លះ ជាពិសេសលើកយកទ្រឹស្តីគតិយុត្តដែល ពាក់ព័ន្ធមកធ្វើការបង្ហាញថាតើផ្ទុយទៅនឹងការអនុវត្តជាក់ស្តែងយ៉ាងដូចម្តេច។

[1] មាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

វិសាលភាពនៃការស្រាវជ្រាវស្តីអំពី **ការលែងលះនៅកម្ពុជាបច្ចុប្បន្ន** គឺផ្តោតសំខាន់ទៅលើសហាព័ន្ធដែលមានចំណងអាពាហ៍ពិពាហ៍ ហើយចំនុចដែលត្រូវលើកមកសិក្សាគឺ សញ្ញាណនៃការលែងលះ មូលហេតុនៃការលែងលះ នីតិវិធីនៃការលែងលះ និង អានុភាពនៃការលែងលះ ដែលស្ថិតនៅក្រោមវិសាលភាពនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ និង ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ នៃព្រះរាជាណាចក្រកម្ពុជាដែលកំពុងអនុវត្តសព្វថ្ងៃមកធ្វើការបកស្រាយតែប៉ុណ្ណោះ។

ទាក់ទិនទៅនឹងប្រធានបទសារណាស្តីអំពី ការលែងលះនៅកម្ពុជាបច្ចុប្បន្ននេះ ត្រូវបានបែងចែកជា៣ជំពូកដែលក្នុងនោះគឺ

**ជំពូកទី១៖ សញ្ញាណនៃការលែងលះ**

**ជំពូកទី២៖ នីតិវិធីនៃការលែងលះដោយការព្រមព្រៀង**

**ជំពូកទី៣៖ នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង**

# ជំពូកទី១

# សញ្ញាណនៃការលែងលះ

ការរៀបអាពាហ៍ពិពាហ៍ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ។ អាពាហ៍ពិពាហ៍ ត្រូវបានចាត់ទុកជាកិច្ចសន្យាឱឡារិកមួយដែលធ្វើឡើងដោយគូស្រករពីរនាក់ បុរស និងនារី ហើយប្ដេជ្ញាថានឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយបានតាមទំនើងចិត្តរបស់ខ្លួន[2]។ ដោយហេតុថាកិច្ចសន្យានេះជាកិច្ចសន្យាឱឡារិក អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍ស្របទៅតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ជាធរមាន។ ក្នុងន័យនេះអាពាហ៍ពិពាហ៍មិនមែនត្រឹមជាការបំពេញតួនាទីតាមក្រឹត្យក្រមច្បាប់ និង បទបញ្ញត្តិប៉ុណ្ណោះទេ ប៉ុន្តែក៏តាមក្រឹត្យក្រមធម្មជាតិផងដែរ។ គួរបញ្ជាក់ផងដែរថា បុរស និងនារីមានសេរីភាពពេញលេញ ក្នុងការជ្រើសរើសគូស្រករក្នុងការកសាងគ្រួសារ រួមរស់សុខទុក្ខនឹងគ្នា និងជាមួយកូនចៅរបស់ខ្លួន។ ប៉ុន្តែចំណងអាពាហ៍ពិពាហ៍បែរជាជួបបញ្ហាល្អក់កករដោយសារ ការរស់នៅមិនចុះសម្រុងនឹងគ្នាដោយសារហេតុផលច្រើនយ៉ាងដូចជា ទស្សនទានខ្វែងគំនិតគ្នា ការប្រើប្រាស់ហិង្សា ការជេរប្រមាថជាដើម ដែលអាចឈានទៅរកការចែកផ្លូវគ្នាតាមរយៈការលែងលះ។ ដូច្នេះមានតែតុលាការទេដែលអាចសម្រេចរឿងលែងលះបាន។

## ១.១. និយមន័យនៃការលែងលះ

**ការលែងលះ** គឺជាការផ្ដាច់ចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធ ដែលបានរៀបការពេញលក្ខណៈច្បាប់ ពេលដែលអ្នកទាំងពីរកំពុងរស់នៅជាមួយគ្នា អាស្រ័យដោយសហព័ទ្ធទាំងសងខាងព្រមព្រៀងគ្នា ឬសហព័ទ្ធណាម្ខាង ដោយមិនអាចរួមរស់នៅជាមួយគ្នាដោយមានសុភមង្គលបាន ក៏ធ្វើសំណូមពរសុំដាច់សមគ្គសង្វាស នឹងត្រូវបានតុលាការសម្រេចតាមបញ្ញត្តិច្បាប់។ ទាក់ទិននឹងការឲ្យនិយមន័យពាក្យថាការលែងលះនេះផងដែរ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលចូលជាធរមាននៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ ហើយត្រូវបានកំពុងអនុវត្តសព្វថ្ងៃនេះមិនមានមាត្រាណាមួយបានបញ្ញត្តិផ្ដល់និយមន័យជាក់លាក់ចំពោះអត្ថន័យនៃការលែងលះនេះទេ ពោលគឺមានចែងតែអំពីមូលហេតុនៃការលែងលះតែប៉ុណ្ណោះ។ គួរឲ្យកត់សម្គាល់ផងដែរ ចំពោះការឲ្យនិយមន័យពាក្យថាការលែងលះ គឺមានលក្ខណៈខុសៗគ្នាដូចតទៅ៖

[2] មាត្រា ៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ ១៩៨៩

-យោងតាមវចនានុក្រមសម្តេចសង្ឃជូនណាត **ការលែងលះ** ជាការផ្តាច់ចំណងសមគ្គសង្វាស ដែលប្រកាសដោយសាលក្រមរបស់តុលាការ[3]។

-ចំណែកឯវចនានុក្រម Cambridge បានឲ្យនិយមន័យពាក្យនៃ**ការលែងលះ** យ៉ាងខ្លីថាគឺ ជាការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ [4]។

-និងយោងតាមមាត្រា៣៨ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារឆ្នាំ ១៩៨៩បានឲ្យនិយម ន័យនៃពាក្យថា **ការលែងលះ** គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធដែលបានរៀបការ ពេញច្បាប់ ក្នុងពេលរស់នៅទាំងពីរនាក់។

## ១.២. លក្ខខណ្ឌដែលអាចលែងលះបាន

ការលែងលះអាចធ្វើបានតាមផ្លូវតុលាការលុះត្រាតែភាគីនៃបណ្តឹង គឺជាសហព័ទ្ធដែល មានអត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដែលអ្នកទាំងពីរបានដាក់ពាក្យសុំរៀប អាពាហ៍ពិពាហ៍ និងបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន[5]។ អត្ថិភាព នៃចំណងអាពាហ៍ពិពាហ៍គឺជាមូលដ្ឋានចម្បងដែលធ្វើឲ្យសហព័ទ្ធមានទំនាក់ទំនងគតិយុត្តរវាងគ្នា និងអាចបង្កើតជាក្រុមគ្រួសារជាមួយគ្នាបានតាមក្បួនច្បាប់។ អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍ បានដើរតួជាលក្ខខណ្ឌគ្រឹះនៅក្នុងរឿងក្តីនៃការលែងលះដោយហេតុថា នៅពេលដំណើរការដោះ ស្រាយរឿងក្តីលែងលះ តុលាការតែងតែបង្គាប់ អោយសហព័ទ្ធផ្តល់នូវសំបុត្រអាពាហ៍ពិពាហ៍ ដើម្បីធ្វើការពិនិត្យ។ ក្នុងករណីដែលសហព័ទ្ធមិនបានផ្តល់តាមការបង្គាប់នេះទេ តុលាការនឹងមិន ជឿថាមានអង្គហេតុនៃការបង្កើតចំណងគតិយុត្តឡើយ ដូច្នេះពាក្យបណ្តឹងឬពាក្យសុំនឹងត្រូវបាន ច្រានចោលដោយដីកាសម្រេចហេតុនេះដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍ជាដំបូងសហព័ទ្ធ គឺ ត្រូវមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដែលជាមូលដ្ឋាននៃការដាក់ពាក្យបណ្តឹងលែងលះ។ មានន័យថាអត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍ ត្រូវបញ្ជាក់ដោយសំបុត្រអាពាហ៍ពិពាហ៍ដែលចេញ ដោយមន្ត្រីអត្រានុកូលដ្ឋានតាមការស្នើសុំពីសហព័ទ្ធទាំងពីរ ដូចនេះសហព័ទ្ធណាម្ខាងអាចធ្វើការ ដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបានដើម្បីឲ្យតុលាការធ្វើការសម្រេចបាន។ បន្ថែមពីនេះទៅ ទៀតនោះ ពាក្យបណ្តឹងនោះត្រូវមានមូលហេតុត្រឹមត្រូវដូចដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ត្រង់មាត្រា ៩៧៨។

[3] យោងតាមវចនានុក្រមខ្មែរអង្គរដែលធ្វើការកែសម្រួលពីវចនានុក្រមសម្តេចសង្ឃរាជជូនណាត ទំព័រ ៧៣

[4] Cambridge University Press 1995 Page 403

[5] មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ១.៣. មូលហេតុនៃការលែងលះចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

សហព័ន្ធអាចដាក់ពាក្យបណ្ដឹងលែងលះបាន ប៉ុន្តែអាស្រ័យលើមូលហេតុនោះថាតើជាមូល-ហេតុដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីរឺទេ? ដូច្នេះដើម្បីចង់ដឹងឲ្យកាន់តែជាក់ច្បាស់យើងខ្ញុំនឹងធ្វើការបកស្រាយពីមូលហេតុដែលនាំឲ្យមានការលែងលះនៅចំណុចខាងក្រោមនេះដូចតទៅ៖

### ១.៣.១. ករណីបានប្រព្រឹត្តអំពើផិត នៅលើសហព័ន្ធ

ដោយគោរពទៅលើគោលការណ៍ឯកពន្ធភាព បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ[6]។ មានន័យថាសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ហើយ ពុំអាចរៀបការជាមួយស្ត្រី ឬបុរសដទៃក្រៅពីសហព័ទ្ធខ្លួនដែលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ឡើយ ជាទូទៅបុរសត្រូវមានប្រពន្ធតែមួយ ឯស្ត្រីត្រូវមានប្ដីតែមួយដូចគ្នា ផ្ទុយពីនេះត្រូវចាត់ទុកថាជាអំពើផិត។ អំពើផិតគឺជាការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីសហព័ទ្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្ដីរបស់ខ្លួន[7]។ ករណីសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍នឹងគ្នា ហើយលួចទៅប្រព្រឹត្តអំពើផិតក្បត់ជាមួយស្ត្រី ឬបុរសដទៃក្រៅពីសហព័ទ្ធខ្លួន ដែលផ្ទុយទៅនឹងច្បាប់បានបញ្ញត្តិត្រូវចាត់ទុកថាជាអំពើដែលមានពិរុទ្ធផងដែរ[8]។ ការប្រព្រឹត្តអំពើផិតគឺជាលក្ខខណ្ឌដែលសហព័ទ្ធម្ខាងដែលទទួលរងនូវការបំពានសិទ្ធិ អាចដាក់ពាក្យបណ្ដឹងលែងលះបាន។ ឧទាហរណ៍ A បានរៀបអាពាហ៍ពិពាហ៍ជាមួយ B ២ឆ្នាំក្រោយមក A បានមានសម្ព័ន្ធភាពផ្លូវភេទជាមួយនឹងនារី C រឿងនេះបានដឹងដល់ B គាត់មានការឈឺចិត្តយ៉ាងខ្លាំង និងលែងចង់រួមរស់នៅជាមួយ A តទៅទៀត ក្នុងករណីនេះ B អាចលែងលះជាមួយ Aបានប្រព្រឹត្តអំពើផិត។

### ១.៣.២. ករណីបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ

ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវដោយភាគីណាម្ខាងនៃសហព័ទ្ធគឺជាហេតុផលមួយនៃការមិនរួមរស់ជីវភាពជាមួយគ្នា សហការគ្នា និងសង្គ្រោះគ្នាទៅវិញទៅមកដូចមានបញ្ញត្តិនៅក្នុងមាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណី នេះសរបញ្ជាក់ឲ្យឃើញថាភាគីនោះគ្មានឆន្ទៈបន្តជីវភាពរស់នៅជាប្ដីប្រពន្ធតទៅទៀតនោះទេ។ ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹម

[6] មាត្រា ៩៥៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[7] មាត្រា ៣ នៃច្បាប់ស្ដីពីឯកពន្ធភាពចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៦

[8] មាត្រា ៦ នៃច្បាប់ស្ដីពីឯកពន្ធភាពចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៦

ត្រូវ គឺជាលក្ខខណ្ឌដែលអាចឲ្យភាគីម្ខាងនៃជនដែលត្រូវបានបំពានសិទ្ធិ ហើយជាជនរងគ្រោះថែម ទៀតនោះអាចមានហេតុផលគ្រប់គ្រាន់ក្នុងការអះអាងសិទ្ធិរបស់ខ្លួន នៅចំពោះមុខតុលាការ។

ឧទាហរណ៍ទី១៖ A(ប្ដី) B(ប្រពន្ធ) បានឈ្លោះទាស់ទែងគ្នា Aបានបណ្ដេញBឲ្យចេញពីផ្ទះ Bគ្មានកន្លែងស្នាក់នៅ បានទៅរស់នៅផ្ទះម្ដាយគាត់អស់រយៈពេល១ឆ្នាំហើយ ទំនាក់ទំនងរវាង A និង B នៅតែមិនត្រូវគ្នា ក្នុងករណីនេះ Bអាចទាមទារឲ្យលែងលះបាន។ឧទាហរណ៍ទី២ A (ប្ដី) បានឈ្លោះទាស់ទែងជាមួយ B (ប្រពន្ធ) ហើយAបានប្រមូលទ្រព្យសម្បត្តិទាំងអស់ចាកចេញទៅ ករណីនេះក៏ត្រូវរាប់ចូលក្នុងករណីបោះបង់សហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវដែរ។

### ១.៣.៣. ករណីមិនបានដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង ០១ឆ្នាំ

នៅត្រង់ចំណុចនេះជាករណីដែលសហព័ទ្ធម្ខាងមិនបានទទួលដំណឹងពីសហព័ទ្ធណាម្ខាង ទៀតដែលបានចាកចេញពីទីលំនៅរបស់ខ្លួនទៅបំពេញការងារ ឬភារកិច្ចណាមួយ ហើយការចាក ចេញនោះទៅបាត់សូន្យឈឹងមិនដឹងថាទៅដល់ទីណាធ្វើអ្វីនៅកន្លែងណានោះទេ គឺគ្មានដំណឹងអស់ រយៈពេលជាង ០១ឆ្នាំក្រោយពីថ្ងៃចាកចេញនោះ។ ទាក់ទិនទៅនឹងបញ្ហាខាងលើនេះ សហព័ទ្ធម្ខាង ទៀតអាចដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីលែងលះដោយបញ្ជាក់ពីអំឡុងពេលដែលសហព័ទ្ធម្ខាង ទៀតបានចាកចេញ ហើយបាត់ដំណឹងសូន្យមិនឃើញត្រឡប់មកវិញមកដល់ពេលបច្ចុប្បន្ន ដែលនេះ ជាលក្ខខណ្ឌមួយឆ្លើយតបទៅនឹងការទាមទាររបស់ភាគីម្ខាងនៃជនរងគ្រោះ។ អំឡុងពេលជាង០១ឆ្នាំ គិតចាប់ពីថ្ងៃបន្ទាប់ដែលសហព័ទ្ធចាកចេញហើយមិនបានផ្ដល់ដំណឹងថានៅរស់ ឬស្លាប់ ឬគិតរាប់ ចាប់ពីថ្ងៃដែលសហព័ទ្ធនោះចាកចេញ លើកលែងតែអំឡុងពេលនោះបានចាប់ផ្ដើមពីម៉ោងសូន្យទៅ គឺម៉ោងរំលងអាធ្រាត្ររហូតដល់ពេលបច្ចុប្បន្ន[៩]។

ឧទាហរណ៍៖ A(ប្ដី) បានចាកចេញពីផ្ទះនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ ដោយមិនឃើញ ត្រលប់មកវិញអស់រយៈពេលជាង ០១ឆ្នាំហើយ នៅតែមិនឃើញសហព័ទ្ធត្រលប់មកវិញទេ ក្នុង ករណីនេះB (ប្រពន្ធ) អាចទាមទារឲ្យលែងលះបាន។សំណួរសួរថា តើអំឡុងពេលជាង ០១ឆ្នាំត្រូវ គណនាចាប់ពីពេលណា? អំឡុងពេលជាង ០១ឆ្នាំត្រូវគណនាដោយផ្អែកលើមាត្រា ៣៣១នៃក្រម រដ្ឋប្បវេណី។ ឧទាហរណ៍ A (ប្ដី) នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ បានចាកចេញពីផ្ទះទៅធ្វើការដូច រាល់ដងប៉ុន្តែចាប់តាំងពីថ្ងៃនោះមក A មិនឃើញត្រលប់មកផ្ទះវិញទេ ហើយក៏បាត់ដំណឹងសូន្យមិន ដឹងថាស្លាប់ ឬ រស់ឡើយ ការបាត់ដំណឹងនេះ មានអំឡុងពេលជាង ០១ឆ្នាំហើយគិតចាប់ពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៤រហូតដល់ពេលបច្ចុប្បន្ន។ ប៉ុន្តែប្រសិនបើ សហព័ទ្ធដែលបានបាត់ពីផ្ទះ ដោយជួប

[៩] មាត្រា ៣៣៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

បញ្ហាគ្រោះថ្នាក់ដូចជា ធ្លាក់យន្តហោះជាដើម ហើយគេមិនដឹងថាស្លាប់ ឬរស់ ក្នុងករណីនេះអំឡុងពេលជាង ០១ ឆ្នាំ ត្រូវបានបកស្រាយថាគិតចាប់ពីថ្ងៃដែលបានគ្រោះថ្នាក់នោះបានកើតឡើង។ ដូចនេះតុលាការនឹង សម្រេចពីការប្រកាសអំពីការបាត់ខ្លួនតាមការស្នើសុំពីសហព័ទ្ធម្ខាងទៀតនៃជនរងគ្រោះបាន ដោយគ្រាន់តែបង្ហាញភស្តុតាងដែលអាចបញ្ជាក់អំពីស្ថានភាពដែលបាត់ដំណឹងអំពីសហព័ទ្ធដោយមិនដឹងថា ស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំនោះគ្រប់គ្រាន់ដើម្បីលែងលះ។

### ១.៣.៤. ករណីសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ឆ្នាំ ផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍

ជាទូទៅសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា គឺត្រូវតែរួមរស់នៅជាមួយគ្នាក្នុងដំបូលផ្ទះតែមួយ ។ វាជារឿងចម្លែកទៅវិញទេដែលសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ហើយមិនរួមរស់នៅជាមួយគ្នានោះ ប៉ុន្តែក៏មានករណីលើកលែងមួយចំនួនដែលនៅពេលដែលសហព័ទ្ធនោះ រៀបអាពាហ៍ពិពាហ៍ហើយត្រូវបង្ខំចិត្តត្រូវតែចាកចេញដើម្បីទៅបំពេញការងារណាមួយនៅឆ្ងាយ ដើម្បីបំពេញតម្រូវការនៃជីវភាពរស់នៅ ឬជាការងារដែលចាំបាច់ខានមិនបានដូចជា ការបំពេញការងារជាមន្ត្រីស្ថានទូតជាដើម។ ប៉ុន្តែសំរាប់ការរស់នៅបែកគ្នាជាបន្តបន្ទាប់ក្នុងចំណុចនេះ គឺសំដៅដល់ស្ថានភាពនៃការរស់នៅបែកផ្ទះគ្នាដោយមិនរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធ ហើយលែងមានសម្ព័ន្ធផ្លូវភេទជាមួយគ្នា ដែលផ្ទុយទៅនឹងគោលបំណងអាពាហ៍ពិពាហ៍ដែលចាត់ចូលទៅនឹងករណីនេះ។ ជាទូទៅការរស់នៅបែកគ្នានោះត្រូវបន្តជាប់គ្នារហូតក្នុងន័យនេះ មិនមែនមិនឲ្យឃ្លាតពីគ្នាមួយជំហានសោះឡើយនោះទេ ប៉ុន្តែត្រូវស្ថិតក្នុងអំឡុងពេល ឬរយៈពេលមួយសមរម្យដែលសហព័ទ្ធទទួលយកបាន និងមិនផ្ទុយទៅនឹងគោលបំណងអាពាហ៍ពិពាហ៍។ឧទាហរណ៍ A(ប្តី) B(ប្រពន្ធ) បានឈ្លោះទាស់ទែងគ្នា Aបានចាកចេញពីផ្ទះមករស់នៅផ្ទះឪពុកម្តាយគាត់ មួយអាទិត្យត្រលប់មកផ្ទះម្តង ក្នុងគោលបំណងមកមើលកូន ហើយលែងមានសម្ព័ន្ធផ្លូវភេទជាមួយBចាប់ពីពេលនោះមក ក្នុងករណីនេះA និង B អាចទាមទារលែងលះគ្នាបាន។

### ១.៣.៥. ករណីផ្សេងៗទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិធានឡើងវិញបាន

បញ្ញត្តិចំណុចនេះមានលក្ខណៈទូលាយ និយាយរួមទោះបីជាមូលហេតុទាំងឡាយ ដែលមិនចូលក្នុងចំណុចពី “១.៣.១” ដល់ “១.៣.៤”ខាងលើនេះ គឺស្ថានភាពនោះអាចនឹងត្រូវបានគេរាប់បញ្ចូលទៅក្នុងចំណុច“១.៣.៥”នេះ។ ដើម្បីសម្រេចបញ្ហានេះ តុលាការគប្បីត្រូវពិចារណាដល់ស្ថានភាពនានាដូចជា សកម្មភាពនិងអាកប្បកិរិយារបស់អ្នកទាំងពីរក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដែល

កើតមាន (ការវាយដុំឃោរឃៅ ធ្វើទុកបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬចំពោះបុព្វញាតិរបស់សហព័ទ្ធមានចរិយាផ្ទុយពីសីលធម៌ ឬប្រព្រឹត្តអនាចារ) ដែលបណ្តាលឲ្យបែកបាក់ហើយគ្មានសង្ឃឹមនឹង អាចបដិទានវិញបាន។

## ១.៤. ប្រភេទនៃការលែងលះ

នៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់អំពីការលែងលះមាន ២ប្រភេទគឺ ការលែងលះដោយការព្រមព្រៀង(១.៤.១) និង ការលែងលះដោយគ្មានការព្រមព្រៀង(១.៤.២)។

### ១.៤.១ ការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង គឺជាការលែងលះដែលកើតឡើងចេញពីឆន្ទៈពិតប្រាកដរបស់សហព័ទ្ធទាំងពីរក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍។ ម្យ៉ាងទៀតការលែងលះប្រភេទនេះគឺជាជម្រើសមួយនៃការលែងលះរបស់សហព័ទ្ធ។ បើសិនជាសហព័ទ្ធទាំងពីរដែលមានចំណងអាពាហ៍ពិពាហ៍នឹងគ្នាដែលខ្លួនយល់ឃើញថាមិនអាចរួមរស់នៅជាមួយគ្នា អស់និស្ស័យនឹងគ្នាហើយនិងអស់មនោសញ្ចេតនានឹងគ្នាហើយបានព្រមព្រៀងគ្នារួចជាស្រេចអំពីការលែងលះ អាចដាក់ពាក្យបណ្តឹង (ក្រមបកប្រែខុស) ទៅតុលាការបាន។ ប៉ុន្តែតុលាការអាចឲ្យលែងលះបានក្រោយពីបានយល់ឃើញថា សហព័ទ្ធទាំងសងខាងមានឆន្ទៈពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍[10]។ ឆន្ទៈពិតប្រាកដក្នុងការព្រមព្រៀងលែងលះក្នុងន័យនេះចង់សំដៅដល់ការបង្ហាញឆន្ទៈព្រមព្រៀងដោយស្ម័គ្រចិត្តរបស់គូភាគីទាំងសងខាង ដោយមិនមានវិការៈដូចជា ការគំរាមគំហែង ការឆបោក ការភាន់ច្រឡំ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត អំពើឆ្លៀតឱកាសដោយមានគោលបំណងកេងចំណេញហួសហេតុជាអាទិ៍[11]។ ចំពោះការលែងលះប្រភេទនេះ ដោយពុំពិចារណាទៅលើមូលហេតុនៃការលែងលះដែលកំណត់ដោយក្រមរដ្ឋប្បណីឡើយ ហេតុនេះការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរគឺ ជាលក្ខខណ្ឌចាំបាច់សម្រាប់ឲ្យតុលាការត្រូវធ្វើជាមូលដ្ឋាននៃការពិចារណាក្នុងការវិនិច្ឆ័យដើម្បីចេញដីកាសម្រេចនៃការលែងលះ។

### ១.៤.២. ការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដែលមានមូលហេតុដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី គឺជាការលែងលះដោយមិនមានការព្រមព្រៀង មានន័យថាភាគីម្ខាង(ប្តី/ប្រពន្ធ)នៃអាពាហ៍ពិពាហ៍ មិនមានឆន្ទៈក្នុងការលែងលះ ប៉ុន្តែភាគីម្ខាងទៀតទទូចឲ្យមានការលែងលះ ដោយមិនអាចរួមរស់ជាមួយគ្នា

[10] មាត្រា ៩៧៩ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[11] មាត្រា ៣៤៥ និងមាត្រាបន្តបន្ទាប់ទៀត នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ទៀតបាន។ ម្យ៉ាងទៀតដោយសារទ្រាំមិនបាននឹងភាគីម្ខាងទៀត(ប្តី/ប្រពន្ធ) បានធ្វើអំពើពុំគប្បីមិនសមរម្យណាមួយមិនអាចនឹងអធ្យាស្រ័យបាន ហើយការប្រព្រឹត្តនោះវាជះឥទ្ធិពលខ្លាំងទៅដល់ភាគីម្ខាងនៃជនរងគ្រោះ កូន សាច់ញាតិ នាំឲ្យបាត់បង់នូវសេចក្តីថ្លៃថ្នូរនៅក្នុងគ្រួសារ ហើយក៏ជាមូលហេតុនៃការលែងលះដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីមាត្រា ៩៧៨ កថាខណ្ឌ១ ផងដែរ។ ភាពមិនសុខចិត្តភាគីនៃជនរងគ្រោះដែលទទួលរងនូវអំពើនោះ ក៏បានសម្រេចចិត្តដាក់ពាក្យបណ្តឹងសុំលែងលះ ដើម្បីឲ្យតុលាការធ្វើការវិនិច្ឆ័យហើយចេញសាលក្រមលែងលះឆ្លើយតបនឹងអ្វីដែលភាគីនៃជនរងគ្រោះ ដែលជាដើមបណ្តឹងបានទាមទារនៅក្នុងពាក្យបណ្តឹង។

ដូចនេះបន្ទាប់ពីយើងបានសិក្សានៅក្នុងជំពូកទី១ សញ្ញាណនៃការលែងលះខាងលើនេះរួចមក យើងនឹងបន្តការសិក្សានៅជំពូកទី២ នីតិវិធីនៃការលែងលះដោយការព្រមព្រៀងជាបន្តទៀត។

# ជំពូកទី២
# នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀងត្រូវបានកំណត់នៅក្នុង មាត្រា៣ កថាខណ្ឌទី១ នៃតារាងឧបសម្ព័ន្ធត្រង់ចំណុចទី៥ ផ្នែកទី៤ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ ហេតុនេះចំពោះការលែងលះដោយការព្រមព្រៀងគ្នាត្រូវប្រព្រឹត្តទៅតាមច្បាប់នេះ។

នៅក្នុងរឿងក្តីនៃការលែងលះដោយការព្រមព្រៀងមានតែភាគីប្តីប្រពន្ធទេដែលជាអ្នកចាប់ផ្តើមដំណើរការនីតិវិធីដោះស្រាយដំបូងតាមរយៈការដាក់ពាក្យសុំទៅតុលាការ មិនមែនជារឿងក្តីដែលតុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹងដោយឆន្ទានុសិទ្ធិឡើយ។ មានន័យថាកម្មវត្ថុនៃការសម្រេច និងការចេញដីកា គឺភាគីជាអ្នកកំណត់នៅក្នុងពាក្យសុំ ហើយតុលាការអាចចាប់ផ្តើមជម្រះក្តីបានទាល់តែទទួលបានពាក្យសុំជាមុនសិន។ ទន្ទឹមនឹងពាក្យសុំភាគីត្រូវមានកិច្ចព្រមព្រៀងលែងលះភ្ជាប់មកជាមួយផងដែរ។ ដូចនេះយើងនឹងសិក្សាលម្អិតទៅលើកិច្ចព្រមព្រៀងលែងលះ(២.១) និងពាក្យសុំលែងលះ(២.២)ដូចខាងក្រោមនេះ៖

## ២.១. កិច្ចព្រមព្រៀងលែងលះ

ដើម្បីបញ្ជាក់ពីឆន្ទៈត្រូវគ្នា ភាគីទាំងសងខាងនៃចំណងអាពាហ៍ពិពាហ៍ត្រូវធ្វើកិច្ចព្រមព្រៀងលែងលះ។ កិច្ចព្រមព្រៀងលែងលះនេះ គឺជាលិខិតមួយដែលគូរភាគីទាំងពីរ(ប្តី/ប្រពន្ធ)បានព្រមព្រៀងគ្នាធ្វើដោយឆន្ទៈដោយពុំមានការបង្ខិតបង្ខំពីភាគីណាម្ខាងឡើយ។ នៅក្នុងកិច្ចព្រមព្រៀងលែងលះនេះ ភាគីប្តីប្រពន្ធអាចធ្វើជាទម្រង់នៃការសម្តែងឆន្ទៈព្រមព្រៀងលែងលះស្តែងឡើងក្រោមរូបភាពពីរគឺ ព្រមព្រៀងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

**ទម្រង់ជាលាយលក្ខណ៍អក្សរ៖** សហព័ទ្ធទាំងពីរអាចរៀបចំកិច្ចព្រមព្រៀងលែងលះគ្នាជាមុនហើយភ្ជាប់ទៅជាមួយពេលយកពាក្យសុំដាក់នៅតុលាការ។ ជាទូទៅកិច្ចព្រមព្រៀងនេះ ភាគច្រើនសរសេរនូវខ្លឹមសារជាសារធាតុចម្បង គឺឆន្ទៈនៃការព្រមព្រៀងលែងលះ និងជាយថាហេតុ ការបែងចែកសិទ្ធិអំណាចមេបាលើកូន បន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូន ការបែងចែកទ្រព្យសម្បត្តិរួម និងការនាំយកពាក្យសុំទៅដាក់នៅតុលាការមានសមត្ថកិច្ចដើម្បីទទួលបានដីកាសម្រេចជាអាទិ៍។

**ទម្រង់ដោយផ្ទាល់មាត់៖** ទម្រង់នេះភាគច្រើនត្រូវបានប្រើប្រាស់ដោយប្រជាជនដែលមិនសូវយល់ដឹងអំពីច្បាប់ និងមិនមានលទ្ធភាពពឹងពាក់មេធាវី។ តាមរយៈទម្រង់នេះ នៅពេលដែលប្តីប្រពន្ធសម្រេចថាលែងលះគ្នា ពួកគាត់បណ្តើរគ្នាទៅតុលាការហើយថ្លែងការណ៍អំពីឆន្ទៈនៃការព្រម

ព្រៀងលែងលះរបស់ខ្លួន នៅចំពោះមុខក្រឡាបញ្ជីដែលទទួលពាក្យសុំនោះតំណាលគ្នានឹងដាក់ពាក្យសុំ។

តាមទ្រឹស្តីពិតរបស់ច្បាប់ ឆន្ទៈនៃការព្រមព្រៀងរបស់ប្តីប្រពន្ធគឺជារឿងដ៏សំខាន់បំផុតដែលចៅក្រមត្រូវការវែកញែក និងស្រាវជ្រាវដើម្បីទទួលស្គាល់ ថាតើការព្រមព្រៀងនោះបានការពារនូវផលប្រយោជន៍រៀងៗខ្លួនរបស់ភាគីដោយយុត្តិធម៌ ឬនៅ (ពិសេសភាគីខាងប្រពន្ធ) ពីព្រោះនៅក្នុងសង្គមខ្មែរបច្ចុប្បន្នអំពើហិង្សាក្នុងគ្រួសារដែលតែងតែកើតឡើងជាញឹកញាប់។

### ២.២. ពាក្យសុំលែងលះ

នៅក្នុងពាក្យសុំលែងលះដោយការព្រមព្រៀងភាគីណាម្ខាងដែលមានគោលបំណងចង់ដាក់ពាក្យសុំលែងលះ អាចដាក់ទៅតុលាការតែត្រូវបំពេញទម្រង់បែបបទនៃការដាក់ពាក្យសុំតាមបញ្ញត្តិច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងបានកំណត់។ ពាក្យសុំលែងលះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ (២.២.១) ឬដោយផ្ទាល់មាត់ក៏បាន (២.២.២) លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត[12]។

#### ២.២.១.ពាក្យសុំជាលាយលក្ខណ៍អក្សរ

ពាក្យសុំលែងលះអាចត្រូវបានធ្វើឡើងដោយអ្នកដាក់ពាក្យសុំ ឬតាមរយៈអ្នកតំណាងដោយអាណត្តិរបស់ខ្លួនក៏បានប្រសិនបើអ្នកដាក់ពាក្យសុំបានស្នើសុំឲ្យមានដោយខ្លួនរបស់គេផ្ទាល់។ ម្យ៉ាងទៀតអ្នកដាក់ពាក្យសុំ ឬអ្នកតំណាងដោយអាណត្តិ ត្រូវរៀបចំលិខិតនៃពាក្យសុំមុននឹងដាក់ទៅតុលាការត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ៖

- **ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកដាក់ពាក្យសុំ ៖** ប្តី ឬប្រពន្ធដែលយកពាក្យសុំមកដាក់ត្រូវសរសេរឈ្មោះ ភេទ អាយុ សញ្ជាតិ និងត្រូវសរសេរអាស័យដ្ឋាន(ផ្ទះលេខ… ផ្លូវ… ក្រុម…ភូមិ… ឃុំ/សង្កាត់…ក្រុង/ស្រុក/ខណ្ឌ…ខេត្ត/រាជធានី…)នៅក្នុងពាក្យសុំ។ ប៉ុន្តែប្រសិនបើមានអ្នកតំណាងដោយអាណត្តិដែលច្បាប់បានកំណត់ត្រូវសរសេរឈ្មោះ និង អាស័យដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះនៅក្នុងពាក្យសុំផងដែរ។

- **ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារៈ** ជាការសរសេរនូវអ្វីដែលអ្នកដាក់ពាក្យសុំបានទាមទារ ហើយក៏ជាការបញ្ជាក់អំពីទំហំនៃរឿងក្តីដែលត្រូវឲ្យតុលាការលើកយកមកវិនិច្ឆ័យ និងសម្រេចសេចក្តីផងដែរ។ ទាក់ទិននឹងខ្លឹមសារនៃការសរសេរពាក្យសុំលែងលះដោយការព្រមព្រៀងចំណុចនេះ ត្រូវសរសេរឲ្យបានដាក់លាក់ថាស្នើសុំឲ្យតុលាការចេញដីកាសម្រេចតាម

[12] មាត្រា ២៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

ពាក្យសុំឲ្យអ្នកដាក់ពាក្យសុំលែងលះជាមួយភាគីម្ខាងទៀត (ការទាមទារចម្បង) និងជាយថាហេតុការទាមទារផ្សេងទៀតដូចជា ការបែងចែកសិទ្ធិអំណាចមេបាលើកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនរបស់អ្នកដែលមិនមានសិទ្ធិអំណាចមេបា ការទទួលបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ឬការបែងចែកទ្រព្យសម្បត្តិ (ការទាមទារបន្ទាប់បន្សំ)ជាអាទិ៍។

**-អង្គហេតុជាមូលហេតុនៃការទាមទារ** ៖ គឺសរសេរជាមូលដ្ឋានគតិយុត្តនៃការទាមទាររបស់ភាគី។ ក្នុងរឿងក្តីនៃការលែងលះដោយការព្រមព្រៀង មូលដ្ឋានគតិយុត្តនៃការទាមទារដូចជា ការលែងលះ ជាអង្គហេតុដែលអាចទាមទារលែងលះបាន គឺអង្គហេតុនៃការកើតឡើងនៃចំណងអាពាហ៍ពិពាហ៍ដែលបញ្ជាក់តាមសំបុត្រអាពាហ៍ពិពាហ៍ និងអង្គហេតុនៃការសម្តែងឆន្ទៈនៃការព្រមព្រៀងលែងលះគ្នា ដែលបញ្ជាក់ដោយកិច្ចព្រមព្រៀង ឬការអះអាងរបស់ភាគី។ រីឯការចាត់ចែងចំពោះកូន ជាអង្គហេតុដែលអាចទាមទារឲ្យតុលាការសម្រេចចាត់ចែងចំពោះកូន គឺជាអង្គហេតុដែលបញ្ជាក់ថា តាមចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធបានបង្កើតកូនដែលបច្ចុប្បន្នជាអនីតិជនដែលអង្គហេតុនេះជាទូទៅអាចបញ្ជាក់ដោយសំបុត្រកំណើតរបស់កូន។ លើសពីនេះទៅទៀត គឺការចាត់ចែងទ្រព្យសម្បត្តិ គឺជាអង្គហេតុដែលអាចទាមទារឲ្យមានការចាត់ចែងទ្រព្យសម្បត្តិ គឺជាអង្គហេតុដែលបញ្ជាក់ពីការមានទ្រព្យសម្បត្តិរួមគ្នា(ទ្រព្យអកម្ម និង ទ្រព្យសកម្ម) ដែលអង្គហេតុបញ្ជាក់ដោយឯកសារនានាដូចជា ប័ណ្ណសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ ឬ លិខិតម្ចាស់យានយន្តជាអាទិ៍។

នៅក្នុងការអនុវត្តជាក់ស្តែង ទម្រង់នៃពាក្យសុំនេះ គឺមិនបានសរសេរឲ្យបានត្រឹមត្រូវតាមស្មារតីនេះទេ ហើយការប្រើប្រាស់ពាក្យក៏មិនបានត្រឹមត្រូវដែរ ជាពិសេសការហៅឈ្មោះភាគីនៅក្នុងរឿងក្តីលែងលះដោយការព្រមព្រៀង គឺ ជនដាក់ពាក្យសុំ ឬអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត មិនមែនដើមចោទ និង ចុងចម្លើយដូចនីតិវិធីបណ្តឹងធម្មតាទេ។

### ២.២.២. ពាក្យសុំដោយផ្ទាល់មាត់

ក្នុងករណីដែលភាគីម្ខាងនៃអ្នកដាក់ពាក្យសុំដែលមានភាពចាំបាច់ណាមួយមិនបានបំពេញទៅតាមលក្ខខណ្ឌទម្រង់ខាងលើនេះ ដូច្នេះពួកគាត់អាចធ្វើពាក្យសុំដោយផ្ទាល់មាត់ ដោយគ្រាន់តែអ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុច (២.២.១) ដែលមានរៀបរាប់ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជីដែលទទួលពាក្យសុំហើយក្រឡាបញ្ជីនោះ ធ្វើការកត់ត្រាទុកនៅក្នុងកំណត់ហេតុ។ កំណត់ហេតុនេះត្រូវចាត់ទុកថាជាលិខិតនៃពាក្យសុំ[13]។ នៅពេលដាក់ពាក្យសុំ ប្រសិនបើអ្នក

[13] មាត្រា ២៦ កថាខណ្ឌ៣ នៃច្បាប់ស្តីពីនិតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១១

ដាក់ពាក្យសុំមានភស្តុតាងជាឯកសារដូចជា សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ សំបុត្របញ្ជាក់កំណើតកូន ឬឯកសារនានាដែលបញ្ជាក់ពីទ្រព្យសម្បត្តិជាអាទិ៍ គាត់ត្រូវដាក់ជូនតុលាការនូវឯកសារច្បាប់ដើម ឬឯកសារដែលមានសេចក្តីបញ្ជាក់ដើម្បីឲ្យតុលាការងាយស្រួលក្នុងការពិនិត្យ និងឆាប់ទទួលស្គាល់អង្គហេតុ។

## ២.៣. សមត្ថកិច្ចដោះស្រាយ

### ២.៣.១. ក្រុមប្រឹក្សាឃុំ សង្កាត់

នៅក្នុងដំណាក់កាលនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់មិនមានសមត្ថកិច្ចអ្វីសម្រេចឲ្យគូភាគីលែងលះគ្នា បែងចែកទ្រព្យសម្បត្តិ កំណត់អ្នកមានអំណាចមេបាលើកូន និងការបង់អាហារកិច្ចនោះឡើយ។ ការដាក់ពាក្យសុំទៅក្រុមប្រឹក្សាឃុំ-សង្កាត់ គ្រាន់តែជាជម្រើសរបស់ភាគីប៉ុណ្ណោះ ពោលគឺថាសហព័ទ្ធអាចដាក់ពាក្យសុំដោយផ្ទាល់ទៅតុលាការមានសមត្ថកិច្ចតែម្តងក៏បាន។ ប៉ុន្តែប្រសិនបើភាគីណាម្ខាងបានសម្រេចចិត្តដាក់ពាក្យសុំមកកាន់ក្រុមប្រឹក្សាឃុំ-សង្កាត់នាលំនៅឋានប្តី ឬប្រពន្ធ ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវដើរតួនាទីជាកិច្ចបឋមគឺ ជាអ្នកផ្សះផ្សាគូភាគីជាមុនសិន។ ការផ្សះផ្សាគឺ ក្នុងគោលបំណងដើម្បីឲ្យគូភាគីត្រូវរ៉ូវគ្នា ហើយធ្វើការសះជានឹងគ្នាដើម្បីបន្តការរស់នៅក្នុងជីវភាពជាប្តីប្រពន្ធសារជាថ្មី។ ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវតែខិតខំធ្វើយ៉ាងណាក្នុងការបញ្ចុះបញ្ចូលគូរភាគីឲ្យសះជានឹងគ្នាបានក្នុងអំឡុងពេលតាមការកំណត់របស់ច្បាប់ ១៥ ថ្ងៃបន្ទាប់ពីបានទទួលពាក្យសុំនោះ[14]។ ប្រសិនបើគូភាគីត្រូវរ៉ូវគ្នា ក្រោយពីទទួលបានការផ្សះផ្សាពីក្រុមប្រឹក្សាឃុំ-សង្កាត់នាំឲ្យគូភាគីយល់ព្រមសះជានឹងគ្នា ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវកត់ត្រាពីអ្វីដែលគូភាគីបានសះជានឹងគ្នានោះទុកធ្វើជាកំណត់ហេតុ និងធ្វើលិខិតកិច្ចសន្យាឲ្យភាគីទាំងពីរដើម្បីទទួលយកការផ្សះផ្សា។ ទន្ទឹមនឹងការផ្សះផ្សានេះ ប្រសិនបើការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់បានធ្វើអស់ពីលទ្ធភាពហើយ គូភាគីនៅតែទទូចចង់ធ្វើការលែងលះ ហើយគ្មានសង្ឃឹមថានឹងអាចសះជានឹងគ្នាដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់មានតែធ្វើការបញ្ជូនពាក្យសុំទៅតុលាការដើម្បីឲ្យតុលាការមានចំណាត់ការបន្ត។

### ២.៣.២. សាលាដំបូងរាជធានី-ខេត្ត

ក្រោយពីក្រុមប្រឹក្សាឃុំ-សង្កាត់ធ្វើការផ្សះផ្សាមិនបានសម្រេច ហើយពាក្យសុំក៏ត្រូវបានបញ្ជូនមកតុលាការនៃលំនៅឋានរបស់ប្តីឬប្រពន្ធនោះ ដូច្នេះតុលាការនឹងបន្តចំណាត់ការនេះពីព្រោះថាមានតែតុលាការទេដែលអាចសម្រេចឲ្យគូភាគីលែងលះគ្នា ឬមិនអាចលែងលះគ្នាបានដោយការចេញដីកា

[14] មាត្រា ៩៨២ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

សម្រេចតាមពាក្យសុំ។ មុននឹងឈានទៅដល់ដំណើរការនីតិវិធីជំនុំជម្រះដោយចៅក្រម ដែលបានទទួលតាមលំដាប់វេនដែលបានកំណត់ទុកជាមុនដោយដីកាសម្រេចប្រចាំឆ្នាំតាមការកំណត់មាត្រា ២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូចនេះពាក្យសុំនោះត្រូវឆ្លងកាត់ការពិនិត្យជាមុនសិន។

**២.៣.២.១. ការពិនិត្យពាក្យសុំ**

នៅពេលដែលពាក្យសុំត្រូវបានដាក់មកដល់តុលាការ អ្នកដែលមានសមត្ថកិច្ចទទួលពាក្យសុំគឺមន្ត្រីរដ្ឋបាល ដែលជាអ្នកទទួលបន្ទុកនៅក្នុងការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិកប្រចាំតុលាការ ។ នៅពេលដែលពាក្យសុំបានបញ្ជូនមកដល់ដៃក្រឡាបញ្ជីដោយមន្ត្រីរដ្ឋបាល ហើយតួនាទីរបស់ក្រឡាបញ្ជីគឺត្រូវធ្វើការពិនិត្យហើយធ្វើការចុះលេខលើសំណុំរឿងដែលបានទទួលនោះ។ ក្នុងករណីដែលពិនិត្យឃើញថាពាក្យសុំនោះមិនត្រឹមត្រូវតាមទម្រង់នៃច្បាប់ដែលបានកំណត់ទេនោះ គឺត្រូវរាយការណ៍ជូនចៅក្រមដើម្បីឲ្យចៅក្រមសម្រេច ថាតើត្រូវបង្គាប់ឲ្យកែតម្រូវ ឬលើកពាក្យសុំចោល(ដីកាសម្រេច)។ ផ្ទុយមកវិញប្រសិនបើពិនិត្យឃើញថាពាក្យសុំនោះត្រឹមត្រូវតាមទម្រង់នៃច្បាប់បានកំណត់ហើយ ដូច្នេះក្រឡាបញ្ជីត្រូវបញ្ជូនពាក្យសុំនោះទៅចៅក្រមដើម្បីសម្រេចបើកការជំនុំជម្រះ។ គួរបញ្ជាក់ផងដែរក្នុងការដាក់ពាក្យសុំ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធលើពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់) រៀល[15]។ ចំណែកឯប្រាក់ប្រដាប់ក្តីក្រៅពីពន្ធគឺ ជាបន្ទុករបស់អ្នកដាក់ពាក្យសុំ[16]។

**២.៣.២.២. ការកោះហៅគូភាគី**

ក្រោយពីពិនិត្យពាក្យសុំឃើញថាត្រឹមត្រូវហើយនោះ តុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទកោះហៅគូភាគីឲ្យចូលមកតុលាការដើម្បីដំណើរការនីតិវិធីរឿងក្តីលែងលះនោះ។ ដូចនេះសាមីភាគីត្រូវមានករណីកិច្ចចូលមកបង្ហាញខ្លួននៅក្នុងតុលាការតាមដីកាកោះឲ្យចូលតាមកាលបរិច្ឆេទដែលបានកំណត់។ ក្នុងករណីដែលត្រូវបានកោះហៅដោយតុលាការដែលបានរៀបរាប់ខាងលើនេះមិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេនោះ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀលបាន[17]។ ការកោះហៅនេះ ដើម្បីឲ្យអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត អះអាងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ឬ ដើម្បីប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ឃើញចាំបាច់ តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់

[15] មាត្រា ២២ កថាខណ្ឌ១ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[16] មាត្រា ២២ កថាខណ្ឌ៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[17] មាត្រា២៩ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

ឃើញចាំបាច់បាន ដោយកំណត់កាលបរិច្ឆេទ។ចំពោះកាលបរិច្ឆេទដើម្បីឲ្យអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀតអះអាង តុលាការទទួលស្គាល់ឲ្យសាមីខ្លួនពឹងអ្នកតំណាងដោយអាណត្តិបង្ហាញខ្លួនជំនួសដោយមិនចាំបាច់បង្ហាញខ្លួនចំពោះមុខតុលាការដូចនីតិវិធីរដ្ឋប្បវេណីដែរ(កថាខណ្ឌទី ១ មាត្រា ៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ប៉ុន្តែចំពោះកាលបរិច្ឆេទប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់វិញមានភាពចាំបាច់ឲ្យសាមីខ្លួនដែលត្រូវបានកោះហៅ បង្ហាញខ្លួនមកតុលាការ និងពន្យល់តុលាការអំពីកាលៈទេសៈមិនមែនដោយអ្នកតំណាងដោយអាណត្តិទេ គឺដោយផ្ទាល់ខ្លួនដើម្បីឲ្យតុលាការក្តោបនូវអង្គហេតុពិតនៅក្នុងរឿងក្តី។ ម្យ៉ាងទៀត ក្នុងករណីដែលសាមីខ្លួនត្រូវបង្ហាញខ្លួន អ្នកតំណាងដោយអាណត្តិក៏អាចចូលរួមជាមួយសាមីខ្លួនបានដែរ។

### ២.៣.២.៣. ការផ្សះផ្សានៅតុលាការ

នៅក្នុងការដឹកនាំនីតិវិធីនៃរឿងក្តីលែងលះដោយការព្រមព្រៀងដែលជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងត្រូវដឹកនាំដោយចៅក្រម។ នៅពេលដែលភាគីបានបង្ហាញខ្លួនតាមការកោះហៅរបស់ចៅក្រម ហើយបានប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតរួចហើយ បន្ទាប់មកចៅក្រមដែលទទួលបន្ទុកលើសំណុំរឿងនោះ នឹងចាប់ផ្តើមដំណើរការដឹកនាំរឿងក្តីនេះតាមពាក្យសុំ របស់អ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ឬជនផ្សេងទៀតនោះ។នៅពេលដឹកនាំនីតិវិធី ទោះបីជារឿងក្តីនៃការលែងលះដោយការព្រមព្រៀងជាការសម្តែងឆន្ទៈរបស់ភាគីក៏ដោយ ក៏ចៅក្រមតែងតែព្យាយាមផ្សះផ្សាភាគីឲ្យត្រូវរ៉ូវគ្នាវិញ បើចៅក្រមពិនិត្យឃើញថាការលែងលះនោះអាចបង្កជាផលអវិជ្ជមានខ្លាំងចំពោះកូន ហើយភាគីនៅមានមនោសញ្ចេតនាជាមួយគ្នានៅឡើយ។ ការផ្សះផ្សានេះ មិនមែនធ្វើដើម្បីឲ្យភាគីសះជានឹងគ្នាដោយការលះបង់ការទាមទារ ឬទទួលស្គាល់ការទាមទារនោះទេ គឺផ្សះផ្សាដើម្បីឲ្យមានការដកពាក្យសុំលែងលះទៅវិញហើយទៅរួមរស់នៅជាប្តីប្រពន្ធនឹងគ្នាតទៅទៀត។ ប៉ុន្តែបើការផ្សះផ្សាម្តងហើយម្តងទៀតនៅក្នុងដំណាក់កាលនីមួយៗមិនបានសម្រេចទេនោះ ចៅក្រមនឹងបន្តសម្រេចសេចក្តីតាមឆន្ទៈរបស់គូភាគីនៃអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ឬជនផ្សេងទៀតនោះ។

### ២.៣.២.៤. ការទាញហេតុផលដោយផ្ទាល់មាត់ និងការសាកសួរដោយឆន្ទានុសិទ្ធិ

នៅក្នុងដំណើរការនីតិវិធីនៃរឿងក្តីលែងលះដោយការព្រមព្រៀង តុលាការអាចធ្វើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនធ្វើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដោយឆន្ទានុសិទ្ធិតាមការយល់ឃើញចាំបាច់ ឬមិនចាំបាច់បាន។ មានន័យថាចំពោះរឿងក្តី ឬចំណុចណាដែលត្រូវ

សម្រេចដោយដីកាសម្រេច តុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលផ្ទាល់មាត់ ឬមិនត្រូវធ្វើ។ ប៉ុន្តែប្រសិនបើតុលាការមិនធ្វើនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ទេនោះ ដូចនេះតុលាការអាចធ្វើនីតិវិធីសាកសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀតនោះ ជំនួសឲ្យនីតិវិធីនោះបាន។ ជាគោលការណ៍ការធ្វើនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ត្រូវធ្វើនៅក្នុងសាលសវនាការ ចំណែកឯនីតិវិធីនៃការសាកសួរអាចធ្វើឡើងក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់ចៅក្រម។ បន្ថែមពីនេះទៅទៀតទាក់ទិននឹងនីតិវិធីការសាកសួរ ក្រៅពីការផ្តល់វេទិកាដល់ភាគីបញ្ជាក់ឲ្យកាន់តែច្បាស់លាស់នូវឆន្ទៈព្រមព្រៀងរបស់ខ្លួនលើគ្រប់បញ្ហាដែលបានទាមទារ តុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ឬ ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិទៀតផង[18]។ មានន័យថាក្នុងការដឹកនាំនីតិវិធីនេះ តុលាការមិនឈរលើគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគីដូចការអនុវត្តក្នុងនីតិវិធីបណ្តឹងធម្មតាឡើយ ពោលគឺតុលាការអាចលើកយកអង្គហេតុដែលភាគីមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន។ លើស-ពីនេះទៅទៀត ក្នុងករណីដែលយល់ឃើញថាសមរម្យ តុលាការអាចអនុញ្ញាតឲ្យជនដែលពាក់ព័ន្ធផលប្រយោជន៍ចូលរួមក្នុងនីតិវិធី ឬចូលស្តាប់ជាអ្នកសង្កេតការណ៍បាន[19]។ម្យ៉ាងទៀតច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ក៏បានអនុញ្ញាតឲ្យតំណាងអយ្យការចូលរួមក្នុងនីតិវិធីតាមរយៈការជូនដំណឹងរបស់តុលាការ ឬចូលរួមដោយឯកឯងប្រសិនបើរឿងក្តីមានការពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ។

## ២.៤. ការចេញដីកាសម្រេច

នៅក្នុងរឿងក្តីលែងលះតាមការព្រមព្រៀង ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយដីកាសម្រេច។ តាមបញ្ញត្តិច្បាប់ដើម្បីចេញដីកាសម្រេចអំពីរឿងក្តី តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ពីព្រោះរឿងក្តីប្រភេទនេះជារឿងក្តីដែលមិនភាពស្មុគស្មាញ និងគ្មានចំណុចវិវាទ ដោយហេតុថាភាគីបានព្រមព្រៀងគ្នារួចរាល់។ ម្យ៉ាងទៀតការលែងលះ គឺជារក្សាការសម្ងាត់ផ្ទាល់ខ្លួនរបស់ភាគី ហេតុនេះហើយដើម្បីចេញដីកាសម្រេចឲ្យលែងលះតាមការព្រមព្រៀងមិនចាំបាច់ទាញហេតុផលជាសាធារណៈឡើយ។ ប៉ុន្តែក្នុងករណីដែលតុលាការយល់ឃើញចាំបាច់សម្រាប់នីតិវិធីនេះ តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដោយឆន្ទានុសិទ្ធិបាន។ ដីកាសម្រេចឲ្យលែងលះតាមការព្រមព្រៀង ដែលជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងជាគោលការណ៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវសរសេរសេចក្តីសម្រេចបញ្ចប់ និងសំអាងហេតុ

[18] មាត្រា ២៧ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[19] មាត្រា ២៨ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនោះ[20]។ ដីកាសម្រេចនេះនឹងមានតម្លៃដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរ។

នៅក្នុងការសម្រេចសេចក្តីនេះដែរ អ្វីដែលជាមូលដ្ឋានដែលចៅក្រមលើកយកមកសម្រេចអំពីការលែងលះនោះ គឺចៅក្រមធ្វើការពិចារណាទៅលើចំនុចជាច្រើនដែលក្នុងនោះជាដំបូងនោះគឺចៅក្រមពិចារណាទៅលើស្ថានភាពគតិយុត្តនៃទំនាក់ទំនងប្តីប្រពន្ធនៃការលែងលះនោះ មានន័យថាតើប្តីប្រពន្ធនោះរៀបការត្រឹមត្រូវតាមច្បាប់ដូចជា បានចុះសំបុត្រអាពាហ៍ពិពាហ៍ជាដើមដែលអាចបញ្ជាក់បានថា ការរៀបអាពាហ៍ពិពាហ៍ដោយមានការទទួលស្គាល់ដោយច្បាប់។ បន្ទាប់មកចៅក្រមពិចារណាទៅលើឆន្ទះព្រមព្រៀងរបស់ភាគី ប្តីប្រពន្ធដែលបានលើកឡើងនៅក្នុងកិច្ចព្រមព្រៀងលែងលះថាតើភាគីប្តីប្រពន្ធនោះពិតជាមានឆន្ទះពិតប្រាកដក្នុងការលែងលះដែរឬទេ? បើចៅក្រមធ្វើការសាកសួរហើយយល់ឃើញថា ភាគីប្តីប្រពន្ធមិនមានឆន្ទៈពិតប្រាកដក្នុងការលែងលះនោះទេ ដូចនេះជាចំណាត់ការចំពោះរឿងក្តីនៃការលែងលះនោះមិនអាចប្រព្រឹត្តទៅរួចទេ ពោលគឺចៅក្រមនឹងចេញដីកាសម្រេចលើកពាក្យសុំចោលដើម្បីបញ្ចប់នីតិវិធីលែងលះនេះ[21]។ ក្នុងករណីបែបនេះចៅក្រមមិនធ្វើការសម្រេចតាមឆន្ទៈព្រមព្រៀងរបស់ភាគីប្តីប្រពន្ធនោះទេ ដោយចៅក្រមអាចសម្រេចពីការលែងលះនេះបានលុះត្រា មានការព្រមព្រៀងពិតប្រាកដពីភាគីនៃការលែងលះ។ លើសពីនេះទៅទៀតចៅក្រមធ្វើការពិចារណាទៅលើចំណុចនៃការទាមទារចម្បងរបស់ភាគីគឺ ការលែងលះ និងជាយថាហេតុការទាមទារបន្ទាប់បន្សំផ្សេងទៀតដូចជា ការបែងចែកសិទ្ធិអំណាចមេបាលើកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនរបស់អ្នកដែលមិនមានសិទ្ធិអំណាចមេបា ការទទួលបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ឬការបែងចែកទ្រព្យសម្បត្តិ បំណុលជាអាទិ៍។ ប៉ុន្តែពុំមានការលំបាកឡើយដោយហេតុថាការលែងលះដោយការព្រមព្រៀងគឺ ភាគីបានព្រមព្រៀងគ្នារួចជាស្រេចទៅលើចំណុចទាំងនេះ ព្រោះថាការលែងលះដោយការព្រមព្រៀងអាចប្រព្រឹត្តទៅបានលុះត្រាតែភាគីបានព្រមព្រៀងគ្នាគ្រប់ចំណុចទើបបាន តែបើមិនមានការព្រមព្រៀងលើគ្រប់ចំណុចទេ ការសម្រេចសេចក្តីមិនអាចធ្វើទៅបានឡើយ។

ទោះក្នុងស្ថានភាពបែបណាក៏ដោយ តុលាការអាចនឹងធ្វើការពិចារណាទៅលើចំណុចដូចខាងលើបានលុះត្រាមានការស្នើសុំពីសហព័ទ្ធ ផ្ទុយមកវិញប្រសិនបើភាគីនៃការលែងលះមិនបានលើកឡើងចំណុចនីមួយៗក្នុងកិច្ចព្រមព្រៀង ឬដោយផ្ទាល់មាត់ក៏ដោយតុលាការមិនធ្វើការ

[20] មាត្រា ៣៥ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

[21] មាត្រា ៣៩ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

ពិចារណាឡើយ ប៉ុន្តែចំណុចដែលតុលាការត្រូវពិចារណាគឺ ឆន្ទៈព្រមព្រៀងលែងលះរបស់ភាគីប៉ុណ្ណោះ។ចំណែកចំណុចដែលភាគីមិនបានព្រមព្រៀងលើបញ្ហាបែងចែកទ្រព្យ ឬ បែងចែកកូនមិនមែនជាឧបសគ្គដល់ការសម្រេចសេចក្តីឡើយ។

ដីកាសម្រេចលើពាក្យសុំលែងលះដោយការព្រមព្រៀង ជាដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដែលត្រូវធ្វើការជូនដំណឹងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេច ទៅភាគីនៃការលែងលះដែលសាមីខ្លួនក្នុងរឿងលែងលះនេះតែម្តង[22]។ ទាក់ទិនទៅនឹងការជូនដំណឹងនេះ មិនចាំបាច់ដាច់ខាតត្រូវតែធ្វើតាមរយៈការបញ្ជូនដែលតម្រូវឲ្យក្រឡាបញ្ជីត្រូវប្រគល់ដោយផ្ទាល់ដោយយោងតាមបញ្ញត្តិមាត្រា ២៥១នៃក្រមរដ្ឋប្បវេណីដូចជា ការបញ្ជូនសាលក្រម ឬសាលដីកានោះទេគឺអាចធ្វើឡើងតាមរយៈការផ្ញើតាមប្រៃសណីយ៍ធម្មតាជាដើមក៏បាន។ ម្យ៉ាងទៀតដីកាសម្រេចលើពាក្យសុំឲ្យលែងលះតាមការព្រមព្រៀងក៏ដូចជា ដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីដែលមិនមែនជាបណ្តឹងមានលក្ខណៈខុសគ្នានឹងដីកាសម្រេចនៅក្នុងបណ្តឹងរដ្ឋប្បវេណីនៅត្រង់ថា ដីកាសម្រេចអំពីអង្គសេចក្តីនៃរឿងក្តីដែលមិនមែនជាបណ្តឹងមានអានុភាពដោយការចូលជាស្ថាពរ មិនមែនដោយការជូនដំណឹងទេ[23]។ មានន័យថាដីកាសម្រេចលើពាក្យសុំលែងលះតាមការព្រមព្រៀង ក៏ដូចជាដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវបានចូលជាស្ថាពរមានអានុភាពអនុវត្តនៅពេលផុតរយៈពេលប្តឹងជំទាស់មានរយៈពេល ០២សប្តាហ៍ គិតចាប់ពីបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ[24]។

## ២.៥. អានុភាពនៃការលែងលះដោយការព្រមព្រៀង

នៅពេលដែលដីកាសម្រេចចូលជាស្ថាពរ អានុភាពនៃដីកាសម្រេចក៏កើតមាន ហើយអានុភាពដែលកើតមាននោះសម្រេចក្រោមរូបភាពឆ្លើយតបនឹងពាក្យសុំរបស់ភាគីដែលបានព្រមព្រៀងគ្នាលើគ្រប់ចំណុចនៅក្នុងការលែងលះដែលមានដូចតទៅ៖

### ២.៥.១. អានុភាពលើទ្រព្យសម្បត្តិ និងភាតព្វកិច្ច

#### ២.៥.១.១ អានុភាពលើទ្រព្យសម្បត្តិ

+ប្រព័ន្ធទ្រព្យដែលកំណត់ដោយច្បាប់លែងយកមកអនុវត្ត

ដោយយោងតាមមាត្រា ៩៨០នៃក្រមរដ្ឋប្បវេណីបញ្ញត្តិអំពីការបែងចែកទ្រព្យសម្បត្តិ ក្នុងករណីប្តីប្រពន្ធដែលបានលែងលះគ្នា ត្រូវធ្វើការបែងចែកទ្រព្យដោយយុត្តិធម៌ផ្អែកតាមការពិភាក្សា

[22] មាត្រា ៣៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០
[23] មាត្រា ៣៧ កថាខណ្ឌ៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០
[24] មាត្រា ៤០ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

របស់គូភាគីទាំងសងខាង។ ដោយឡែកការលែងលះដោយការព្រមព្រៀង គឺគូភាគីតែងតែធ្វើការពិភាក្សាក្នុងការបែងចែកទ្រព្យសម្បត្តិរួមដោយមាន ទាំងទ្រព្យសកម្ម និងទ្រព្យអកម្មដោយខ្លួនឯង។ ចំពោះទ្រព្យដោយឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយករៀងៗខ្លួន។

**២.៥.១.២ អានុភាពលើកាតព្វកិច្ច**

+ ការបញ្ចប់កាតព្វកិច្ចដែលទាមទារដោយច្បាប់

កាតព្វកិច្ចរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក ប្តីប្រពន្ធដែលមានករណីកិច្ច ស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សា និងជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាពគ្រួសារ ព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល ហើយមានសិទ្ធិស្មើគ្នាមានករណីសហការគ្នា ដើម្បីថែរក្សាជីវភាពអាពាហ៍ពិពាហ៍រួម[25]។ ប៉ុន្តែអ្វីៗទាំងអស់នេះនឹងបញ្ចប់ដោយការលែងលះគ្នា។

+កាតព្វកិច្ចបង់សោហ៊ុយចាំបាច់ចិញ្ចឹមកូន

ឪពុក ឬ ម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា[26]។ ប៉ុន្តែនៅក្រោយការលះលែង គឺត្រូវមានភាគីណាម្ខាងជាអ្នកមានសិទ្ធិអំណាចមេបាលើកូនដែលគេហៅថា អំណាចមេបាទោល។ ដោយសារតែការបែងចែកកូនមានការពាក់ព័ន្ធនឹងអាហារកាតព្វកិច្ចចិញ្ចឹមកូន ហេតុនេះហើយបានជានៅក្រោយពេលលែងលះតុលាការត្រូវពិចារណា ហើយសម្រេចឲ្យភាគីណាម្ខាង ឪពុក ឬ ម្តាយជាអ្នកមានអំណាចមេបាលើកូន។ ក្នុងករណីតុលាការកំណត់ម្តាយជាអ្នកមានអំណាចមេបា ម្តាយត្រូវចាត់ទុកថា អ្នកមានសិទ្ធិលើសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន ហើយឪពុកត្រូវចាត់ទុកថា អ្នកមានករណីកិច្ចបង់សោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន។ តុលាការធ្វើការសម្រេចអំពីចំនួននៃសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន ដោយពិចារណាស្ថានភាពនៃជីវភាព និងសេដ្ឋកិច្ចរបស់ឪពុកឬម្តាយ ដែលមានករណីកិច្ចត្រូវបង់នោះ។ ប៉ុន្តែនៅក្នុងរឿងក្តីលែងលះដោយការព្រមព្រៀង គឺគូភាគីតែងបានព្រមព្រៀងគ្នារួចជាស្រេច មិនមានអ្វីដែលឱ្យតុលាការពិបាកសម្រេចឡើយ។

[25] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[26] មាត្រា ១០៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ២.៥.២. អានុភាពលើស្ថានភាពគ្រួសារ

### ២.៥.២.១ ការកំណត់អ្នកមានអំណាចមេបា

កូនដែលបានកើតក្នុងចំណងអាពាហ៍ពិពាហ៍ ហើយដែលនៅក្នុងស្ថានភាពជាអនីតិជននៅឡើយពេលដែលមានការលែងលះរវាងប្ដី និងប្រពន្ធត្រូវកំណត់យកឪពុក ឬម្ដាយណាម្ខាងជាអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្ដាយ។ ក្នុងករណីដែលឪពុកម្ដាយបានលែងលះគ្នានៅមុនកំណើតកូន ម្ដាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ ប៉ុន្តែនៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្ដាយបាន[27]។ ក៏ប៉ុន្តែចំពោះករណីលែងលះដោយការព្រមព្រៀង គឺវាមានភាពងាយស្រួលក្នុងការសម្រេចអំពីអ្នកមានអំណាចមេបាលើកូនដោយហេតុថា គូភាគីតែងតែកំណត់ជ្រើសរើសរួចជាស្រេច ផ្ទុយមកវិញបើសហព័ទ្ធពុំមានការយល់ព្រមតាមការពិភាក្សាទេនោះ នោះតុលាការនឹងធ្វើការពិចារណាថ្លឹងថ្លែងពីផលប្រយោជន៍កូន។

### ២.៥.២.២ អានុភាពនៃអត្តាធិនភាពនៅតែមាន

ក្នុងករណីដែលអនីតិជន ដែលបានទទួលអត្តាធិនភាពដោយការរៀបអាពាហ៍ពិពាហ៍ ហើយបានលែងលះគ្នា អានុភាពនៃអត្តាធិនភាពនៅតែមានដដែល ពុំបានបញ្ចប់តាមអនុភាពការលែងលះនោះទេ[28]។

### ២.៥.២.៣ ការបញ្ចប់ទំនាក់ទំនងញាតិពន្ធ

នៅពេលដែលមានការរំលាយចំណងអាពាហ៍ពិពាហ៍ដោយការលែងលះ នោះទំនាក់ទំនងញាតិពន្ធក៏ត្រូវបានបញ្ចប់រវាងសហព័ទ្ធទាំងសងខាងផងដែរ[29]។ ត្រង់ចំណុចនេះអានុភាពនៃការរំលាយចំណងអាពាហ៍ពិពាហ៍ដោយការលែងលះ គឺមានភាពខុសគ្នាទៅនឹងការរំលាយចំណងអាពាហ៍ពិពាហ៍ ដោយសារមរណភាពរបស់សហព័ទ្ធណាម្ខាងដោយទំនាក់ទំនងញាតិពន្ធមិនបញ្ចប់នោះទេ លុះត្រាតែសហព័ទ្ធដែលនៅរស់រៀបអាពាហ៍ពិពាហ៍ថ្មី[30]។

### ២.៥.២.៤ ការបញ្ចប់ ឬ ការប្រែប្រួលនូវការប្រើនាមត្រកូលរបស់សហព័ទ្ធ

ក្រៅពីការបញ្ចប់នូវទំនាក់ទំនងញាតិពន្ធ អានុភាពនៃការរំលាយចំណងអាពាហ៍ពិពាហ៍ដោយការលែងលះក៏ធ្វើឲ្យមានការបញ្ចប់ ឬ ប្រែប្រួលនូវការប្រើនាមត្រកូលរបស់សហព័ទ្ធណាម្ខាងផងដែរ។

[27] មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[28] មាត្រា២១ មាត្រា២២ និងមាត្រា៩៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[29] មាត្រា ៩៤១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[30] មាត្រា ៩៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ដោយច្បាប់បានចែងជាជម្រើសថាប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មីដោយអាពាហ៍ពិពាហ៍អាចប្រើនាមត្រកូលនៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬ អាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាបាន[31]។

ដូចនេះបន្ទាប់ពីបានសិក្សាជំពូកទី២ នីតិវិធីនៃការលែងលះដោយការព្រមព្រៀងខាងលើនេះរួចមក យើងនឹងបន្តការសិក្សានៅជំពូកទី៣ នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀងជាបន្តទៀត។

[31] មាត្រា ៩៨១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

# ជំពូកទី៣
# នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង

## ៣.១. នីតិវិធីនៃបណ្ដឹងលែងលះ

### ៣.១.១ ការផ្ដើមនៃបណ្ដឹងលែងលះ

ចំពោះរឿងក្ដីលែងលះដោយគ្មានការព្រមព្រៀង ដំណើរការនីតិវិធីត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។ បើភាគីណាមួយដែលជាសហព័ទ្ធ(ប្ដី/ប្រពន្ធ) ដែលមានបំណងពិតប្រាកដក្នុងការលែងលះ ដោយផ្អែកលើមូលហេតុត្រឹមត្រូវ អាចដាក់ពាក្យបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ចដោយយោងតាមមាត្រា ១០(សមត្ថកិច្ចជម្រះក្ដីពិសេសលើរឿងក្ដីលែងលះគ្នា និងរឿងក្ដីអំពីបុគ្គលភាព)នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន[32]។ ពោលគឺ សមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ច នៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល ដែលពាក់ពន្ធ័នឹងបណ្ដឹងនោះ។ ម្យ៉ាងទៀតតុលាការអាចដំណើរការរឿងក្ដីនេះបាន តាមរយៈការដាក់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង ហើយនៅក្នុងពាក្យបណ្ដឹងត្រូវសរសេរឲ្យបានត្រឹមត្រូវតាមលក្ខខណ្ឌទម្រង់ដែលច្បាប់បានកំណត់ផងដែរ។

#### ៣.១.១.១ ការសរសេរពាក្យបណ្ដឹងលែងលះ

ការសរសេរពាក្យបណ្ដឹងលែងលះត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយត្រូវរៀបរាប់អំពីមូលហេតុដែលសហព័ទ្ធសុំលែងលះគ្នា ហើយត្រូវចុះហត្ថលេខាដោយសហព័ទ្ធដែលជាអ្នកប្ដឹង។ សហព័ទ្ធដែលជាអ្នកប្ដឹងហៅថា ភាគីដើមបណ្ដឹង ឬ ដើមចោទ រីឯសហព័ទ្ធដែលទទួលរងការប្ដឹងនោះហៅថា ចុងចម្លើយ។

នៅក្នុងពាក្យបណ្ដឹងលែងលះ ត្រូវធ្វើឡើងដោយ សរសេរនូវរាល់ចំនុចដូចដែលមានចែងនៅក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះការសរសេរពាក្យបណ្ដឹងលែងលះដែលធ្វើឡើងជាលាយលក្ខណ៍អក្សរមិនខុសគ្នាទៅនឹងការសរសេរពាក្យសុំលែងលះនៅជំពូកទី២ ខាងលើនោះទេ គឺត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់។

ដោយយោងទៅតាមសេចក្ដីប្រកាសរបស់ក្រសួងយុត្តិធម៌ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០៧ ភាគីដើមចោទត្រូវបង់ពន្ធពាក្យបណ្ដឹងលែងលះត្រូវបង់ចំនួន ៥៥០០០រៀល នៅពេលដែលពាក្យបណ្ដឹងត្រូវបានដាក់មកតុលាការ។ បន្ថែមពីនេះទៅទៀត ភាគីដើមចោទត្រូវបង់ប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធ ដូចជាចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការពិនិត្យភស្តុតាងការបញ្ជូនឯកសារ

[32] មាត្រា ៩៨២ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ឬចំនួនទឹកប្រាក់សម្រាប់សោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅរបស់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីមានការពិនិត្យភស្តុតាង និងសោហ៊ុយសកម្មភាពផ្សេងទៀតតាមនីតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី ដើម្បីដំណើរការស៊ើបអង្កេតរឿងនោះ[33]។ ចំពោះចំនួនប្រាក់ប្រដាប់ក្តីសម្រាប់ភាគីដែលទទួលបន្ទុកចេញ គឺភាគីដែលចាញ់ក្តីជាអ្នកទទួលបន្ទុកចេញសងវិញ [34]។

**កំណត់សម្គាល់** បណ្តឹងរដ្ឋប្បវេណីទូទៅ ច្បាប់តម្រូវឱ្យភាគីនីមួយៗ ជាអ្នកស្វែងរកភស្តុតាងដាក់ជូនទៅតុលាការដោយខ្លួនឯង ហើយនៅក្នុងពាក្យបណ្តឹង បើភាគីទាមទារចំណុចណា តុលាការនឹងសម្រេចសេចក្តីតាមពាក្យសុំត្រង់ចំណុចនោះ ដោយផ្អែកលើភស្តុតាងដែលភាគីបានបង្ហាញដល់តុលាការប៉ុណ្ណោះ។ ដោយឡែកចំពោះចំណុចណាដែលភាគីមិនបានទាមទារ ឬភ្លេចទាមទារ តុលាការមិនសម្រេចចំណុចដែលមិនបានទាមទារឡើយ។

### ៣.១.១.២ កន្លែងទទួលពាក្យបណ្តឹង

ជាទូទៅបណ្តឹងនៃការលែងលះ ទីកន្លែងនៃការដាក់ពាក្យបណ្តឹងមានពីរ ដើម្បីឱ្យភាគីជ្រើសរើសដាក់ពាក្យបណ្តឹងសុំលែងលះ។ ដូចនេះភាគីអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅតុលាការរាជធានី ឬខេត្ត ឬក្រុមប្រឹក្សាឃុំ-សង្កាត់នៃលំនៅឋានភាគីរបស់ប្តី ឬប្រពន្ធ។

ករណីដែលលំនៅឋានរបស់ភាគីមិនស្ថិតនៅក្នុងប្រទេសកម្ពុជា ឬលំនៅឋាននៅប្រទេសកម្ពុជាមិនពិតប្រាកដទេ តុលាការដែលមានសមត្ថកិច្ចជម្រះក្តីជាអ្នកកំណត់តាមទីសំណាក់របស់ភាគីចុងចម្លើយ។ បើពុំមានទីសំណាក់ ឬទីសំណាក់មិនពិតប្រាកដទេនោះ តុលាការត្រូវកំណត់តាមលំនៅឋានចុងក្រោយ[35]។ ហេតុផលនៃតម្រូវការនេះ គឺដើម្បីធានាថាចុងចម្លើយនឹងបានទទួលការជូនដំណឹងថា ប្តី ឬប្រពន្ធរបស់គេបានដាក់ពាក្យប្តឹងសុំលែងលះរូបគេហើយ។

បើសិនជាភាគីដើមចោទ និងភាគីចុងចម្លើយរស់នៅកន្លែងជាមួយគ្នានោះ វិធាននេះនឹងមិនបង្កើតជាបញ្ហាអ្វីទេ។ ប៉ុន្តែ បើសិនជាភាគីដើមចោទ និងចុងចម្លើយរស់នៅដោយឡែកពីគ្នា វិធាននេះអាចនឹងបង្កការលំបាកដល់សហព័ទ្ធដើមចោទ។ ការលំបាកអាចកើតឡើង បើសិនជាសហព័ទ្ធដើមចោទត្រូវធ្វើដំណើរយ៉ាងឆ្ងាយដើម្បីដាក់ពាក្យប្តឹង និងដើម្បីចូលរួមនៅក្នុងនីតិវិធី។ លើសនេះទៅទៀតសហព័ទ្ធដើមចោទអាចនឹងមិនដឹងពីទីកន្លែងដែលចុងចម្លើយរស់នៅ។ ការលំបាកនឹងអាចកើតឡើងដែរប្រសិនបើមេឃុំ ឬចៅសង្កាត់ស្គាល់ហើយមានទំនាក់ទំនងល្អជាមួយចុងចម្លើយដោយ

---

[33] មាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[34] មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[35] មាត្រា ៨និង មាត្រា ១០នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

ហេតុថាគេរស់នៅក្នុងសហគមន៍ជាមួយគ្នា ហើយមន្ត្រីទាំងនោះមិនបានស្គាល់សហព័ទ្ធដើមចោទ ដែលនៅឆ្ងាយពីនោះ។ សភាពការណ៍បែបនេះ នឹងអាចបង្កឱ្យមានការលម្អៀងទៅរកចុងចម្លើយ។

**៣.១.២ ការផ្សះផ្សា**

ក្រោយពេលដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ឬតុលាការបានទទួលពាក្យបណ្ដឹងជាផ្លូវការ ដែលភាគីទាមទារលែងលះគ្នាហើយក្រុមប្រឹក្សាឃុំ-សង្កាត់ និងតុលាការត្រូវមាននីតិវិធីសំខាន់មួយគឺ ការផ្សះផ្សា។ ប៉ុន្តែអ្វីដែលសំខាន់មុននឹងធ្វើការផ្សះផ្សាត្រូវពិនិត្យមើលសំណុំឯកសារដែលពាក់ព័ន្ធ គឺសំបុត្រអាពាហ៍ពិពាហ៍ ដើម្បីបញ្ជាក់ថាពួកគេពិតជាប្ដី ប្រពន្ធស្របច្បាប់។

**៣.១.២.១ ការផ្សះផ្សានៅថ្នាក់ឃុំ សង្កាត់**

ដូចគ្នាទៅនឹងការលែងលះដោយមានការព្រមព្រៀងដែរ ប្រសិនបើភាគីណាម្ខាង(ប្ដី/ប្រពន្ធ) បានដាក់ពាក្យបណ្ដឹងទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ឲ្យដោះស្រាយមុនដាក់ទៅតុលាការ មន្ត្រីទាំងនោះត្រូវសាកល្បងធ្វើការផ្សះផ្សាក្នុងរយៈពេល ១៥ ថ្ងៃក្រោយពីបានទទួលពាក្យបណ្ដឹង។ ប្រសិនបើភាគីទាំងពីរពុំព្រមបន្តការរួមរស់ជាមួយគ្នាទេ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវចាត់ទុកថា មានពាក្យបណ្ដឹងសុំលែងលះ ហើយក្រុមប្រឹក្សាបញ្ជូនពាក្យបណ្ដឹងទៅតុលាការ"ជាបន្ទាន់"[36]។ ទោះបីជាក្រមរដ្ឋប្បវេណីមិនមានចែងការផ្សះផ្សាត្រូវធ្វើឡើងច្រើនដងក៏ដោយ ប៉ុន្តែនៅក្នុងការអនុវត្តក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងនោះអាចព្យាយាមធ្វើការផ្សះផ្សាជាច្រើនដងមុននឹងបញ្ជូនរឿងនេះទៅតុលាការ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ ពុំមានអំណាចសម្រេចឱ្យមានការលែងលះគ្នា ឬសម្រេចអំពីការថែរក្សាកូន ការជួយផ្គត់ផ្គង់សហព័ទ្ធ ឬការបែងចែកទ្រព្យសម្បត្តិ។

**៣.១.២.២ ការផ្សះផ្សាដោយតុលាការ**

នីតិវិធីនៅតុលាការមានលក្ខណៈដូចគ្នា មិនថាតុលាការទទួលពាក្យបណ្ដឹងដោយផ្ទាល់ពីភាគីដើមចោទ ឬតុលាការទទួលពាក្យបណ្ដឹងពីមេឃុំ-ចៅសង្កាត់ទេ។ ក្រោយពេលទទួលពាក្យបណ្ដឹងតុលាការត្រូវចាត់តាំងចៅក្រមមួយរូបដើម្បីធ្វើការផ្សះផ្សា។

ទោះបីជាសហព័ទ្ធម្ខាង ទាមទារលែងលះគ្នាខ្លាំងយ៉ាងណាក៏ដោយ តុលាការអាចនឹងធ្វើការផ្សះផ្សាដោយឆន្ទានុសិទ្ធិ[37]។ ការផ្សះផ្សានេះ មិនមែនធ្វើដើម្បីឲ្យភាគីសះជានឹងគ្នាដោយការលះបង់ការទាមទារ ឬទទួលស្គាល់ការទាមទារនោះទេ គឺផ្សះផ្សាដើម្បីឲ្យមានការដកពាក្យបណ្ដឹងលែងលះ

[36] មាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[37] មាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ទៅវិញហើយទៅរួមរស់នៅជាប្តីប្រពន្ធនឹងគ្នាតទៅទៀត។ មានន័យថា ចំពោះរឿងក្តីពាក់ព័ន្ធនិងឋានៈបុគ្គលច្បាប់បានហាមឃាត់ចំពោះការផ្សះផ្សាលើបណ្តឹង[38]។

### ៣.១.២.៣. ការហាមឃាត់ការផ្សះផ្សាក្នុងករណីអំពើហិង្សាក្នុងគ្រួសារធ្ងន់ធ្ងរ

ករណីបណ្តឹងលែងលះគ្នា អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការផ្សះផ្សា ក្នុងករណីដែលបណ្តឹងលែងលះគ្នានោះ មិនមានប្រើអំពើហិង្សា ឬករណីមានប្រើអំពើហិង្សាដែលជាបទល្មើសប៉ះពាល់ខាងផ្លូវកាយ ឬផ្លូវចិត្ត និងបទល្មើសមជ្ឈិមស្រាល ឬបទលហុ ការផ្សះផ្សាឬសម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង។ សមាជិកគ្រួសារអាចជ្រើសរើសវិធីណាមួយដោយស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យមេភូមិ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើជាអាជ្ញាកណ្តាលដោះស្រាយបញ្ហា ដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ល្អរបស់ជាតិ និងរក្សានូវចំណងអាពាហ៍ពិពាហ៍ស្របតាមមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា និងមាត្រា ២៦នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

ក្នុងករណីបណ្តឹងលែងលះគ្នាដែលមានលក្ខណៈជាបទល្មើសឧក្រិដ្ឋ ឬជាបទមជ្ឈិមធ្ងន់ធ្ងរ អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីផ្សះផ្សា ឬសម្រុះសម្រួលបានទេ[39]។ អំពើហិង្សាដែលមានចរិកជាបទល្មើសព្រហ្មទណ្ឌ ដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬបទមជ្ឈិមធ្ងន់ធ្ងរ ត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញាទោះបីជាអំពើហិង្សានេះ បានកន្លងទៅហើយក៏ដោយ។

### ៣.១.៣ ការចាត់ចែងរក្សាការពារ

ពេលខ្លះការលែងលះគ្នា គឺត្រូវការពេលវេលាមួយយ៉ាងវែង ជាពិសេសពេលមានការសាកល្បងជាច្រើនលើកដើម្បីផ្សះផ្សាសហព័ទ្ធទាំងនោះ។ នៅពេលមានករណីដូច្នេះ តុលាការអាចនឹងចេញវិធានការបណ្តោះអាសន្ន ***វិធានការចាត់ចែងរក្សាការពារ*** ដើម្បីដោះស្រាយបញ្ហាខ្លះរវាងសហព័ទ្ធនោះ ក្នុងពេលដែលគេរង់ចាំសាលក្រមស្ថាពរនៃការលែងលះ។ វិធានការនេះ គឺជាការណែនាំឬបញ្ជារបស់តុលាការបង្គាប់ទៅភាគីសហព័ទ្ធ ហើយចៅក្រមត្រូវចុះក្នុងកំណត់ត្រារបស់តុលាការ។ វិធានការទាំងនេះមានលក្ខណជា បណ្តោះអាសន្ន ព្រោះមានប្រសិទ្ធភាពតែក្នុងរយៈពេលសំណុំរឿងលែងលះនៅក្នុងស្ថានភាពរង់ចាំ។ នៅពេលដែលតុលាការចេញសាលក្រមស្ថាពរ សាលក្រមស្ថាពរនោះនឹងជំនួសឱ្យវិធានការបណ្តោះអាសន្នរបស់តុលាការ។ ចំពោះមេធាវីនៃគូភាគីត្រូវបាន

[38] មាត្រា ១៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០

[39] មាត្រា ១៧ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០០៥

អនុញ្ញាតឱ្យចូលរួមស្តាប់ក្នុងសវនាការដើម្បីសម្រេចថា ចាំបាច់ត្រូវមាន ឬមិនត្រូវមានវិធានការចាត់ចែងរក្សាការពារ។ យោងតាមមាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ អនុញ្ញាតឱ្យតុលាការចេញវិធានការចាត់ចែងរក្សាការពារ ៥យ៉ាងដូចតទៅនេះ ទី១ វិធានការឱ្យសហព័ទ្ធត្រូវរស់នៅបែកគ្នា ទី២ វិធានការដាក់ឱ្យមានការថែរក្សាកូនបណ្តោះអាសន្ន ទី៣ វិធានការទាក់ទងដល់ការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន ទី៤ វិធានការទាក់ទងទៅនឹងការផ្គត់ផ្គង់សហព័ទ្ធ ឬផ្គត់ផ្គង់កូន និងទី៥ វិធានការរឹបអូសជាបណ្តោះអាសន្ន។

**៣.១.៣.១ វិធានការឱ្យសហព័ទ្ធត្រូវតែរស់នៅបែកគ្នា**

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ អនុញ្ញាតឱ្យតុលាការចេញវិធានការឱ្យភាគីទាំងពីររស់នៅបែកគ្នាបណ្តោះអាសន្ន ក្នុងអំឡុងពេលនៃនីតិវិធីលែងលះគ្នា ក្នុងករណីភាគីទាំងពីរមានប្រើអំពើហិង្សាក្នុងគ្រួសារ។ ប៉ុន្តែក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មិនមានចែងអំពីវិធានការឱ្យសហព័ទ្ធត្រូវតែរស់នៅបែកគ្នាបណ្តោះអាសន្នទេក្នុងករណីភាគីទាំងពីរមានប្រើអំពើហិង្សាក្នុងគ្រួសារ និងបានប្តឹងសុំលែងលះគ្នា តើតុលាការត្រូវដោះស្រាយបណ្តឹងសំអាងលើច្បាប់អ្វី? ករណីនេះប្រហែលជា ពួកគេពឹងផ្អែកទៅលើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលផ្តល់អំណាចទៅឱ្យមេឃុំ ចៅសង្កាត់ក្នុងដំណាក់កាលនៃការជួយអន្តរាគមន៍លើកដំបូង។

មាត្រា ១៥នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានផ្តល់សិទ្ធិអំណាចទៅដល់មេឃុំ ចៅសង្កាត់ អាចចាត់វិធានការបណ្តោះអាសន្នដែលមានដូចជា៖

- ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង។
- ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬរបស់ញាតិសាលោហិតរបស់ជនរងគ្រោះ។
- ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួមកន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច។
- ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពជនរងគ្រោះ និងសមាជិកគ្រួសារ ឬជនបានដែលពាក់ព័ន្ធ។

ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះក៏អាចធ្វើបណ្តឹងទៅតុលាការរាជធានី ខេត្ត ដើម្បីសុំចេញដីកាការពារ។ តុលាការដែលទទួលបណ្តឹងដើម្បីចាត់ការ អាចចេញដីកាការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានសហព័ទ្ធដែលបានប្រើអំពើហិង្សា។

ប្រសិនបើមានអំពើហិង្សាលើរូបរាងកាយប្រពន្ធ ឬកូន ឬក្នុងករណីមានអំពើឃោរឃៅលើស្មារតីធ្ងន់ធ្ងរ ពេលនោះប្រហែលជាប្រពន្ធចង់ស្នើសុំឱ្យភាគីទាំងពីររស់បែកគ្នា ចាប់តាំងពីពេលចាប់ផ្តើមនីតិវិធីលែងលះគ្នា។

នៅពេលប្តីបានប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ហើយជាញឹកញាប់ ការប្រព្រឹត្តអំពើនោះកាន់តែជ្រៅទៅថែមទៀត នៅពេលដែលប្រពន្ធនោះដាក់ មានពាក្យប្តឹងលែងលះ គឺជាការសំខាន់ចំពោះសុវត្ថិភាពប្រពន្ធ និងកូនដែលច្បាប់ត្រូវតែឱ្យប្តីដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ រស់នៅបែកពីអ្នកដែលប្តឹងនោះ។ នៅក្នុងប្រទេសជាច្រើនប្រសិនបើប្តីបានប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ តុលាការអាចហាមឃាត់ប្តីនោះមិនឱ្យចូលផ្ទះទោះបីជាខ្លួនគេជាម្ចាស់ផ្ទះដោយ។

**៣.១.៣.២ វិធានការឱ្យមានការថែរក្សាកូនបណ្តោះអាសន្ន**

ប្រសិនបើភាគីទាំងពីរ មិនព្រមព្រៀងគ្នាលើការថែរក្សាកូនក្នុងកំឡុងពេលនៃនីតិវិធីលែងលះគ្នា ចៅក្រមអាចចេញវិធានការកំណត់ថា តើឪពុក ឬម្តាយដែលត្រូវថែរក្សាកូនជាបណ្តោះអាសន្ន។ ដូចដែលយើងនឹងពិភាក្សាជាលម្អិតនៅពេលក្រោយ ឪពុកម្តាយដែលទទួលភារកិច្ច ថែរក្សាកូន ជាទូទៅមានន័យថា ជាឪពុកម្តាយដែលមានអំណាចធ្វើសេចក្តីសម្រេចទាក់ទងនឹងកូន ដែលច្បាប់ក៏ហៅថា ឪពុកម្តាយមានអំណាចមេបា ហើយជាឪពុកម្តាយដែលរស់នៅជាមួយកូននោះ។

ក្រមរដ្ឋប្បវេណីមិនបានចែងថា ចៅក្រមជាអ្នកត្រូវសម្រេចឪពុក ឬម្តាយថែរក្សាកូនជាបណ្តោះអាសន្នក្នុងអំឡុងពេលនីតិវិធីនៃការលែងលះទេ។ ប្រសិនបើច្បាប់មានចែងពីគោលការណ៍ណែនាំថែមទៀតថា តើតុលាការកំណត់ការថែរក្សាកូនយ៉ាងដូចម្តេចនោះ គឺជាការមួយជួយទាំងចៅក្រមជួយទាំងភាគីផងដែរ។

ទោះបីជាមិនមានចែងនៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ក៏នៅមានប្រភពផ្សេងៗទៀតដែលចៅក្រមអាចយកធ្វើជាមូលដ្ឋានសម្រាប់ការពិចារណាបាន ៖

- ទី១ ចៅក្រមអាចពិនិត្យមើលទៅលើ ប្រពៃណីទំនៀមទម្លាប់ ដើម្បីអាចធ្វើជាប្រភពនៃគោលការណ៍ណែនាំមួយ។
- ទី២ ចៅក្រមអាចពិនិត្យមើលទៅបទដ្ឋានគតិយុត្ត ដែលប្រទេសដទៃទៀតធ្លាប់បានធ្វើ។
- ទី៣ ចៅក្រមអាចមើលទៅច្បាប់អន្តរជាតិដូចជាអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។

### ៣.១.៣.៣ វិធានការស្តីពីការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន

ចៅក្រមមានអំណាចចេញវិធានការបណ្តោះអាសន្នស្តីពីការថែរក្សា ការពារ និងប្រើប្រាស់ទ្រព្យសម្បត្តិក្នុងអំឡុងពេលនីតិវិធីនៃការលែងលះ។ វិធានការនេះសំខាន់ណាស់ ពីព្រោះសហព័ទ្ធមួយអាចព្យាយាមយក ឬក៏លក់ ឬផ្ទេរទ្រព្យសម្បត្តិ មុនពេលដែលតុលាការមានឱកាសស៊ើបអង្កេត និងធ្វើការបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌។ ម្យ៉ាងទៀត ក៏ជួយការពារមិនឱ្យភាគីម្ខាងទៀតលក់ ធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនោះ។ ប្រសិនបើសហព័ទ្ធទាំងពីរជាម្ចាស់ផ្ទះ ចៅក្រមអាចសម្រេចថា អ្នកណានឹងរស់នៅក្នុងផ្ទះនោះ ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីការលែងលះគ្នានោះ។

### ៣.១.៣.៤ វិធានការផ្តល់ការផ្គត់ផ្គង់ហិរញ្ញវត្ថុបណ្តោះអាសន្ន

តុលាការមានអំណាចចេញវិធានការបណ្តោះអាសន្ន ស្តីពីការផ្គត់ផ្គង់កូនបណ្តោះអាសន្ន ហើយក្នុងករណីចាំបាច់ តុលាការក៏អាចសម្រេចឱ្យមានការផ្គត់ផ្គង់ដល់សហព័ទ្ធ។

ជាទូទៅនៅក្នុងប្រទេសកម្ពុជា ក៏ដូចនៅប្រទេសផ្សេងទៀត តុលាការនឹងពិចារណាលើកត្តា ៣យ៉ាង ដូចតទៅនេះ

- សេចក្តីត្រូវការរបស់កូន
- លទ្ធភាពខាងហិរញ្ញវត្ថុរបស់ឪពុក ឬម្តាយដែលត្រូវបានគេស្នើឱ្យសុំឱ្យបង់ប្រាក់ផ្គត់ផ្គង់ ។
- ស្ថានភាពហិរញ្ញវត្ថុរបស់ឪពុក ឬម្តាយដែលកូនត្រូវរស់នៅជាមួយ។ និយាយម្យ៉ាងទៀតគឺថា តើអ្នកណាមានលទ្ធភាពអាចបង់ប្រាក់បាន? យើងនឹងឃើញថាទាំងអស់នេះជាសំនួរដូចគ្នានឹងសំនួរដែលចៅក្រមត្រូវសម្រេចនៅពេលវិនិច្ឆ័យលើការលែងលះគ្នា ប្រសិនបើភាគីទាំងពីរមិនអាចឈានដល់ការព្រមព្រៀងគ្នាបាន អំពីការផ្គត់ផ្គង់ថវិកាដល់ សហព័ទ្ធ និងកូន។

តុលាការក៏អាចផ្តល់ការផ្គត់ផ្គង់បណ្តោះអាសន្ន ដល់សហព័ទ្ធដែលត្រូវការប្រាក់ ក្នុងអំឡុងពេលនីតិវិធីនៃការលែងលះគ្នា។ ម្យ៉ាងទៀត ច្បាប់មិនបានណែនាំតុលាការតើត្រូវសម្រេចផ្តល់ការផ្គត់ផ្គង់ដល់សហព័ទ្ធ ឬក៏មិនផ្តល់ ឬមានទឹកប្រាក់ចំនួនប៉ុន្មានដែលសហព័ទ្ធមួយត្រូវបង់ទៅឱ្យសហព័ទ្ធមួយទៀតជាបណ្តោះអាសន្នទេ។ជាទូទៅតុលាការចេញវិធានការបណ្តោះអាសន្នបើអាចធ្វើបានដើម្បីរក្សាកម្រិតជីវភាពសហព័ទ្ធដែលធ្លាប់ទទួលបានការផ្គត់ផ្គង់ ដូចក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។ វិធានស្តីពីការផ្គត់ផ្គង់សហព័ទ្ធជាបណ្តោះអាសន្ននេះ មិនអនុវត្តជាចាំបាច់ចំពោះការផ្គត់ផ្គង់សហព័ទ្ធជាអចិន្ត្រៃយ៍នោះទេ។

#### ៣.១.៣.៥ ធ្វើការរឹបអូសជាបណ្ដោះអាសន្ន

នៅក្នុងករណីមានបណ្ដឹងលែងលះគ្នា តុលាការក៏អាចចេញវិធានការឱ្យធ្វើការរឹបអូសជាបណ្ដោះអាសន្ននូវទ្រព្យសម្បត្តិដែលជាចលនទ្រព្យ ឬអចលនទ្រព្យរបស់សហព័ទ្ធ ឬវត្ថុតាងណាមួយដោយឆន្ទានុសិទ្ធិបានដែរ ទោះបីភាគីមិនបានស្នើសុំក៏ដោយ។ការនេះមានសារៈសំខាន់យ៉ាងខ្លាំងដើម្បីថែរក្សាទ្រព្យសម្បត្តិ ឬភស្តុតាងនានា ដើម្បីបង្កាកុំឱ្យសហព័ទ្ធម្ខាងទៀតបំផ្លាញ ឬធ្វើឱ្យមានការខូចខាតទ្រព្យសម្បត្តិ ឬមានការចាត់ចែងផ្សេងដូចជាការលក់ដូច ការជួល ឬការបញ្ចាំ ការធ្វើអំណោយជាដើម។

## ៣.២.នីតិវិធីនៃការជម្រះក្ដី

នីតិវិធីនៃការជម្រះក្ដីក្នុងរឿងរដ្ឋប្បវេណី សម្រាប់អាពាហ៍ពិពាហ៍ដែលស្របច្បាប់ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានលក្ខណៈលម្អិតជាងពេលមុនដែលទាមទារឱ្យប្រើពេលវេលាយូរ និងមាននីតិវិធីសាំញ៉ាំជាងមុន។

### ៣.២.១ ការពិនិត្យលើពាក្យបណ្ដឹង

ក្រោយពេលតុលាការបានទទួលពាក្យបណ្ដឹងហើយត្រូវចាត់ការត្រួតពិនិត្យលើពាក្យបណ្ដឹងនោះ ហើយក្នុងករណីចៅក្រមរកឃើញថា ក្នុងពាក្យបណ្ដឹងនោះមានចំណុចខ្វះខាត ដូចជាករណីមិនបានបង់ពន្ធជាដើម តុលាការត្រូវកំណត់ពេលសមរម្យ និងបង្គាប់ឱ្យដើមចោទមកធ្វើការកែតម្រូវចំណុចខ្វះខាតទាំងនោះ[40]។ ប៉ុន្តែក្រមនីតិវិធីរដ្ឋប្បវេណីមិនបានកំណត់ពេលវេលាច្បាស់លាស់ថាមានរយៈពេលប៉ុន្មានដែលតុលាការត្រូវពិនិត្យមើលលើពាក្យបណ្ដឹងនោះថាខ្វះខាតត្រង់ចំណុចណាទេ ដែលជាហេតុនាំឱ្យភាគីត្រូវជួបការលំបាក ព្រោះត្រូវការរង់ចាំរយៈពេលយូរក៏មាន។

### ៣.២.២ ការបញ្ជូនពាក្យបណ្ដឹងទៅចុងចម្លើយ

ប្រសិនបើពាក្យបណ្ដឹងមានលក្ខណត្រឹមត្រូវតាមច្បាប់ហើយតុលាការត្រូវរៀបចំចាត់ការបញ្ជូនពាក្យបណ្ដឹងនោះទៅចុងចម្លើយដើម្បីឱ្យចុងចម្លើយបានដឹង និងត្រូវធ្វើការឆ្លើយតប ឬទប់ទល់វិញ[41]។ ពីព្រោះការបញ្ជូននេះ គឺជាការឱ្យភាគីម្ខាងទៀតបានដឹងអំពីបណ្ដឹងថា តើបុគ្គលណាជាអ្នកប្ដឹង កម្មវត្ថុនៃបណ្ដឹងជាអ្វី និងមធ្យោបាយតទល់របស់អ្នកប្ដឹងនោះជាដើមហើយជាការផ្ដល់ឱកាសឱ្យភាគីម្ខាងទៀតនោះឆ្លើយដោះសារ និងរៀបចំមធ្យោបាយការពារខ្លួន។ ពេលពាក្យបណ្ដឹងត្រូវបានបញ្ជូនទៅដល់ចុងចម្លើយហើយទើបបណ្ដឹងនោះត្រូវបានចាត់ការ។

---

[40]មាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[41]មាត្រា ៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

### ៣.២.៣ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផលលើកដំបូង

នៅពេលពាក្យបណ្តឹងដែលត្រូវបានដាក់នោះ មានគ្រប់លក្ខណៈហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងឆាប់រហ័ស។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផលលើកដំបូងនេះ តុលាការត្រូវកំណត់រយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ដល់តុលាការ ដោយរាប់ទាំងរយៈពេលដែលតុលាការតម្រូវឱ្យធ្វើការកែតម្រូវនូវពាក្យបណ្តឹងផងដែរ។ ប៉ុន្តែក្នុងករណីមានហេតុផលពិសេសផ្សេងៗ ដែលតុលាការមិនអាចធ្វើបាន តុលាការអាចទុករយៈពេលយូរជាងនេះបាន[42]។

### ៣.២.៤ ការលើកពាក្យបណ្តឹងចោល

ក្នុងករណីពាក្យបណ្តឹងលែងលះគ្នាដែលភាគីដើមចោទ បានដាក់ពាក្យបណ្តឹងទៅតុលាការ អាចត្រូវបានតុលាការលើកចោលពាក្យបណ្តឹងនោះមិនយកមកសម្រេចសេចក្តី ដោយដីកាសម្រេចរបស់តុលាការ ក្នុងករណីមានមូលហេតុណាមួយដូចខាងក្រោម[43] ៖

- ដើមចោទមិនបានមកកែតម្រូវលើពាក្យបណ្តឹងតាមការណែនាំរបស់ចៅក្រមលើចំណុចខ្វះខាតនៃពាក្យបណ្តឹងនោះ។
- ពាក្យបណ្តឹងមានលក្ខណផ្ទុយនឹងច្បាប់។

### ៣.២.៥ ការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

ភាគីដើមចោទដែលបានធ្វើបណ្តឹងលែងលះគ្នា អាចបន្ថែម ឬអាចផ្លាស់ប្តូរនូវកម្មវត្ថុ ឬមូលហេតុនៃបណ្តឹងទាមទារបាន រហូតដល់ពេលចប់នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់។ ចំពោះការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង មិនត្រូវធ្វើឱ្យប៉ះពាល់ ឬមានការផ្លាស់ប្តូរមូលដ្ឋាននៃការទាមទារទេ។ ការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ ទើបតុលាការទទួលយកមកពិចារណា ហើយតុលាការក៏អាចបដិសេធមិនទទួលយកការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹងបានដែរ បើតុលាការយល់ឃើញថា ចាំបាច់តាមការសម្រេចដោយឆន្ទានុសិទ្ធិបាន[44]។

### ៣.២.៦ ការប្តឹងតបរបស់ចុងចម្លើយ

ភាគីចុងចម្លើយ អាចប្តឹងតបទៅភាគីដើមចោទវិញបានផងដែរ នៅពេលដែលតុលាការកំពុងចាត់ការបណ្តឹងរបស់ដើមចោទរហូតដល់ពេលចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់ នៃការជម្រះក្តី

[42]មាត្រា ៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
[43]មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
[44]មាត្រា ៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

លើកទី១ ឬការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។ ការធ្វើបណ្តឹងតបនេះបាន លុះត្រាតែការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងតបនេះ មានការទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬជាមធ្យោបាយការពារខ្លួនសម្រាប់តទល់ទៅនឹងបណ្តឹងរបស់ដើមចោទ[45] ។

ប៉ុន្តែការធ្វើបណ្តឹងតបរបស់ចុងចម្លើយនេះ ច្បាប់មិនអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងនោះ ស្ថិតនៅក្នុងសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដទៃទៀតតាមការកំណត់របស់ច្បាប់ ឬករណីដែលការប្តឹងតបនោះវានឹងធ្វើឱ្យមានការយឺតយ៉ាវខ្លាំងនៅក្នុងនីតិវិធីបណ្តឹង។

### ៣.២.៧ ការស៊ើបអង្កេតរបស់ចៅក្រម និងការជម្រះក្តី

ប្រសិនបើការផ្សះផ្សារបស់តុលាការ មិនអាចនាំឱ្យសហព័ទ្ធព្រមព្រៀងគ្នាបន្តការរួមរស់ជាមួយគ្នាបានទេ នោះតុលាការនឹងចេញដីកាកោះហៅសហព័ទ្ធឱ្យមកបង្ហាញខ្លួន ដើម្បីធ្វើការស៊ើបអង្កេត និងវិនិច្ឆ័យពីបណ្តឹងសុំលែងលះ។

នៅក្នុងករណីការលែងលះគ្នាដែលស្នើឡើងដោយភាគីទាំងពីរ តុលាការអាចសម្រេចឱ្យលែងលះគ្នា ប្រសិនបើក្រោយការស៊ើបអង្កេតតុលាការរកឃើញថា សហព័ទ្ធទាំងពីរបានស្នើសុំលែងលះដោយស្ម័គ្រចិត្ត។ នៅក្នុងករណីនេះ គោលបំណងនៃការស៊ើបអង្កេតរបស់តុលាការគឺត្រូវរកឃើញថា តើសហព័ទ្ធមួយត្រូវមានការបង្ខិតបង្ខំរហូតដល់លែងលះគ្នាដែរឬអត់ ឬភាគីបានព្រមព្រៀងដោយស្ម័គ្រចិត្ត។

នៅក្នុងករណីដែលមានតែភាគីមួយ បានស្នើសុំលែងលះគ្នាតុលាការអាចសម្រេចឱ្យលែងលះបាន ប្រសិនបើក្រោយការស៊ើបអង្កេត តុលាការបានរកឃើញស្ថានភាពរវាងប្តីប្រពន្ធមានកំហុសធ្ងន់ធ្ងរបង្ហាញថា ភាគីទាំងពីរមិនអាចរួមរស់ជាមួយគ្នាបាន[46]។ នៅក្នុងករណីនេះ គោលបំណងនៃការស៊ើបអង្កេត គឺដើម្បីកំណត់ថាតើមូលហេតុនោះសមស្រប និងត្រឹមត្រូវតាមច្បាប់ដើម្បីសម្រេចផ្តល់ការលែងលះតាមច្បាប់ដែរ ឬទេ។

ដើម្បីធ្វើការស៊ើបអង្កេតករណីលែងលះគ្នា នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីថ្មីមានដំណាក់កាលជាច្រើនដូចជា:

- ដំណាក់កាលទី១ ដំណើរការទាញហេតុផលផ្ទាល់មាត់

[45] មាត្រា ៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ និងមាត្រា ១២នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ ២០១០

[46] មាត្រា ៩៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

- ដំណាក់កាលទី២ ការត្រៀមឯកសារ
- ដំណាក់កាលទី៣ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
- ដំណាក់កាលទី៤ ការទាញហេតុផលផ្ទាល់មាត់
- ដំណាក់កាលទី៥ ការសម្រេចសេចក្តី។

**៣.២.៧.១.ដំណើរការទាញហេតុផលផ្ទាល់មាត់**

ដើម្បីកំណត់អំពីអង្គហេតុ និងអង្គច្បាប់ឱ្យមានភាពច្បាស់លាស់ទាក់ទងទៅនឹងបណ្តឹង តុលាការត្រូវបង្គាប់ឱ្យភាគីទាំងពីរជូនភស្តុតាងចាំបាច់នានាដល់តុលាការ និងអញ្ជើញសាក្សីឱ្យចូលមកបំភ្លឺរឿងនេះដល់តុលាការ ដើម្បីឱ្យភាគីអះអាង ឬបញ្ជាក់ភស្តុតាងនានាដល់តុលាការ[47]។

នៅក្នុងដំណើរការនេះ ភាគីអាចទាមទារឱ្យតុលាការសាកសួរសំណួរចាំបាច់ទៅភាគីម្ខាងទៀតបាន នៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬការទាញហេតុផលផ្ទាល់មាត់បាន។

ច្បាប់មិនបានកំណត់កាលបរិច្ឆេទនៅក្នុងដំណាក់កាលនៃការទាញហេតុផលផ្ទាល់មាត់នេះទេ។

នៅក្នុងដំណាក់កាលនេះ ភាគីអាចដាក់ជូនតុលាការនូវមធ្យោបាយការពារខ្លួន ឬមធ្យោបាយតទល់ជាមួយភាគីម្ខាងទៀតបាន ដែលធ្វើជាមូលដ្ឋានសម្រាប់ការពិចារណា និងការចេញសាលក្រមរបស់តុលាការ។មធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវដាក់ឲ្យតុលាការនៅពេលណាមួយសមរម្យទៅតាមដំណើរនៃបណ្តឹង[48]។ មធ្យោបាយតទល់ជាអ្វីៗទាំងឡាយដែលភាគីដើមចោទដាក់ទៅតុលាការដើម្បីឱ្យតុលាការយកធ្វើជាមូលដ្ឋាននៃពាក្យសុំ(បណ្តឹង) រីឯមធ្យោបាយការពារខ្លួន គឺជាអ្វីៗទាំងឡាយដែលចុងចម្លើយដាក់ទៅតុលាការ ដើម្បីឱ្យតុលាការយកមកធ្វើជាមូលដ្ឋាននៃពាក្យសុំប្រឆាំងតបវិញ។ នៅក្នុងបណ្តឹងរដ្ឋប្បវេណីទូទៅ នៅក្នុងករណីដែលភាគីបានដាក់នូវមធ្យោបាយការពារខ្លួន ឬមធ្យោបាយតទល់យឺតយ៉ាវ និងមិនត្រូវសមរម្យនឹងពេលវេលា ដោយសារចេតនា ឬដោយកំហុសធ្ងន់ធ្ងររបស់ភាគី ឬមធ្យោបាយនោះមានអត្ថន័យមិនច្បាស់លាស់ តុលាការអាចលើកចោលមធ្យោបាយការពារខ្លួន ឬមធ្យោបាយតទល់នោះ តាមពាក្យស្នើសុំរបស់ភាគី ឬ សម្រេចដោយឆន្ទានុសិទ្ធិរបស់ចៅក្រមផ្ទាល់ ប្រសិនបើចៅក្រមយល់ឃើញថា ការដាក់មធ្យោបាយនោះនាំឱ្យយឺតយ៉ាវក្នុងការបញ្ចប់នៃនីតិវិធីបណ្តឹង[49]។

[47] មាត្រា ៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[48] មាត្រា ៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[49] មាត្រា ៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

**កំណត់សម្គាល់** ក្នុងករណីដែលភាគីណាមួយមិនបានអះអាងអំពីអង្គហេតុដែលខ្លួនមានប្រាប់ដល់តុលាការទេ តុលាការអាចយកអង្គហេតុដែលខ្លួនបានដឹង មកធ្វើជាមូលដ្ឋាននៃការសម្រេចសេចក្តីបាន ពីព្រោះក្នុងរឿងក្តីបណ្តឹងលែងលះគ្នា ភាគីជាអ្នកអះអាងអំពីអង្គហេតុ ជាអ្នកស្វែងរកភស្តុតាងដោយខ្លួនឯង និងជាអ្នកបង្ហាញភស្តុតាងទៅតុលាការដោយខ្លួនឯង ព្រះរាជអាជ្ញា និងតុលាការ ដែលជាអ្នកចូលរួមការអះអាងពីភស្តុតាង អាចស្រាវជ្រាវអង្គហេតុដោយឆន្ទានុសិទ្ធិបាន[50]។

ម្យ៉ាងទៀតនៅក្នុងបណ្តឹងរដ្ឋប្បវេណីទូទៅ ក្នុងករណីដែលភាគីណាមួយមិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលផ្ទាល់មាត់ទេ ច្បាប់ចាត់ទុកថាភាគីនោះបានសារភាពចំពោះអង្គហេតុនោះ។ ប៉ុន្តែសម្រាប់បណ្តឹងលែងលះគ្នា ឬបណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវបានលើកលែងផងដែរចំពោះករណីនេះ ដោយតុលាការមិនអាចសំអាងថា ភាគីមួយទៀតនោះមិនបានតវ៉ា ឬឆ្លើយតប ត្រូវចាត់ទុកថាបានសារភាពនោះទេ។តុលាការត្រូវតែស្វែងរកការពិតដោយការសាកសួរទៅភាគីនោះ ឬស្វែងរកភស្តុតាងតាមមធ្យោបាយផ្សេងទៀត។[51]

### ៣.២.៧.២. ឯកសារត្រៀម

នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀមបាន។

នៅក្នុងឯកសារត្រៀម ភាគីត្រូវសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត។

នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវសរសេរអំពីការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និងអង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង។[52]

តុលាការជាអ្នកកំណត់អំពីពេលវេលាសមស្របសម្រាប់ការដាក់ឯកសារត្រៀមនេះរបស់ដើមចោទ និងឯកសារតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោមធ្យោបាយតទល់ ឬការពារខ្លួន

[50] មាត្រា ៤ និងមាត្រា ១៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

[51] មាត្រា ៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ និងមាត្រា ១៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

[52] មាត្រា ១០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

របស់ភាគីចុងចម្លើយ។ ប៉ុន្តែច្បាប់មិនបានកំណត់ពេលវេលាច្បាស់លាស់សម្រាប់ការដាក់ឯកសារត្រៀមនេះទេ ដើម្បីទុកឱ្យចៅក្រមជាអ្នកមានឆន្ទានុសិទ្ធិកំណត់។

### ៣.២.៧.៣. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺតុលាការត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលភាគីយល់ថា មិនយល់ស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលឱ្យបានល្អិតល្អន់[53]។

នីតិវិធីសម្រាប់ត្រៀមការទាញហេតុផលនេះ ខុសពីនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ដោយសារថា នីតិសម្រាប់ត្រៀមការទាញហេតុផលមិនបាច់ធ្វើនៅក្នុងសាលសវនាការទេ គឺអាចធ្វើនៅក្នុងបន្ទប់ធម្មតាណាមួយ ដែលដាក់ឈ្មោះថាជាបន្ទប់ត្រៀមក៏បានដែរ ប៉ុន្តែតុលាការមិនចាំបាច់ហាមឃាត់អ្នកផ្សេងចូលរួមសង្កេតការណ៍ទេ។

នីតិវិធីសម្រាប់ការត្រៀមទាញហេតុផលនេះ តុលាការក៏ជាអ្នកកំណត់កាលបរិច្ឆេទសមរម្យដែលភាគីទាំងពីរអាចចូលរួមបាន ដើម្បីគោរពគោលការណ៍ចំពោះមុខតុលាការរបស់ភាគី ដែលនឹងបើកឱ្យភាគីអាចចូលរួមទាំងសងខាង។

នៅក្នុងនីតិវិធីនេះ តុលាការក៏អាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំពិនិត្យភស្តុតាង ដូចជាដីកាសម្រេចបង្គាប់ឱ្យដាក់ឯកសារ ការស្នើសុំឱ្យផ្ញើឯកសារ ឬការប្រគល់កិច្ចការកោសលវិច័យ ដីកាសម្រេចយក ឬមិនយកភស្តុតាងដែលភាគីស្នើសុំឱ្យពិនិត្យជាដើម។ តុលាការក៏អាចចេញដីកាសម្រេចផ្សេងៗទៀត ដូចជាការអនុញ្ញាត ឬមិនអនុញ្ញាតបន្ថែម ឬប្តូរកម្មវត្ថុនៃបណ្តឹង ការសម្រេចសេចក្តីស្តីអំពីការអនុញ្ញាតការចូលរួមអន្តរាគមន៍ឬមិនអនុញ្ញាតជាដើម។

នៅក្នុងបណ្តឹងរដ្ឋប្បវេណីទូទៅ ក្រោយពេលបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីបានទៀតទេ។ ប៉ុន្តែតុលាការមានឆន្ទានុសិទ្ធិ និងធ្វើការស្រាវជ្រាវដោយខ្លួនឯង ឬក្នុងករណីដែលការដាក់មធ្យោបាយថ្មីនោះមិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ឬករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ពីដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ នៅមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានទេ។

[53] មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

ប៉ុន្តែសម្រាប់បណ្តឹងលែងលះគ្នា ភាគីដើមចោទនៃបណ្តឹងលែងលះគ្នា នៅតែអាចបន្ថែម ឬផ្លាស់ប្តូរនូវការទាមទារ ឬមូលហេតុនៃការទាមទារបាន ទោះបីជាក្រោយពេលបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះហើយក៏ដោយ ហើយចុងចម្លើយអាចប្តឹងតបបាន រហូតដល់ពេលចប់ការទាញហេតុផលផ្ទាល់មាត់នៃការជម្រះក្តីលើកទី១ ឬការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីទាំងពីរមកចូលរួម[54]។ ប៉ុន្តែច្បាប់មិនបានកំណត់រយៈពេលច្បាស់លាស់ទេ គឺឱ្យចៅក្រមមានឆន្ទានុសិទ្ធិសម្រេចកំណត់ពេលវេលា។

**៣.២.៧.៤. ការទាញហេតុផលដោយផ្ទាល់មាត់**

ដើម្បីចេញសាលក្រមលើបណ្តឹងលែងលះគ្នា តុលាការចាំបាច់ត្រូវឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែចំពោះរឿងក្តី ឬចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេចតុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនធ្វើ។ ក្នុងករណីដែលតុលាការសម្រេចមិនធ្វើការទាញហេតុផលផ្ទាល់មាត់ តុលាការអាចសាកសួរភាគីបាន។[55]

ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន។ ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាក់ទងឋានៈបុគ្គលមិនត្រូវធ្វើជាសាធារណៈឡើយ[56]។

នៅក្នុងនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់នេះដែរ ភាគីទាំងសងខាងត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ដើម្បីចង្អុលបង្ហាញអោយបានច្បាស់នៅអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាង ដែលនឹងត្រូវធ្វើនៅក្នុងការទាញហេតុផលផ្ទាល់មាត់។ ហើយនៅពេលដែលធ្វើការទាញហេតុផលផ្ទាល់មាត់ ភាគីទាំងសងខាងអាចអះអាងអំពីអង្គហេតុ និងអាចដាក់ភស្តុតាងមកទៀតបាន។[57]

- <u>**ភស្តុតាង**</u>

នៅមុនពេលដែលតុលាការសម្រេចសេចក្តី តុលាការត្រូវស្វែងរកភស្តុតាងនានា ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការសម្រេចសេចក្តី។ អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង

[54] មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[55] មាត្រា ១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[56] មាត្រា ១៦ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០

[57] មាត្រា ១១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្តែងតុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះដោយផ្អែកលើភស្តុតាង។ ការស្វែងរកភស្តុតាងនានានោះមានដូចជាៈ

- ភស្តុតាងចេញពីការទាញហេតុផលផ្ទាល់មាត់

ក្នុងដំណើរការនីតិវិធីការទាញហេតុផលផ្ទាល់មាត់ចៅក្រមអាចពិចារណាអំពីស្ថានភាពនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការទទួលស្គាល់អង្គហេតុ ដោយមិនផ្អែកលើភស្តុតាងបាន។

ឧទាហរណ៍: ភាគីវិវាទទៅលើវត្តមាននៃរឿងពិត តែការវិវាទនោះពុំមានលក្ខណៈធ្ងន់ធ្ងរពេកទេ ក្នុងករណីនេះតុលាការអាចទទួលស្គាល់រឿងពិតបានដោយមិនចាំបាច់យោងទៅតាមភស្តុតាង។

តុលាការក៏អាចពិនិត្យភស្តុតាង តាមការស្នើសុំរបស់ភាគី។ ប្រសិនបើតុលាការពុំអាចសម្រេចថាត្រូវទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីបានស្នើសុំឱ្យពិនិត្យ ឬ បើយល់ឃើញថាមានការចាំបាច់ផ្សេងទៀតនោះតុលាការអាចពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន[58]។

- ភស្តុតាងសាក្សី

ដើម្បីតុលាការអាចប្រមូលភស្តុតាងគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ ដោយចៅក្រមអាចសាកសួរជនណាមួយជាសាក្សីក៏បាន។ តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សី ដែលមិនព្រមចូលខ្លួនមកកាន់តុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីកាសម្រេចបាន។ ក្នុងករណីដែលសាក្សីមិនព្រមចូលខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់។ ការពិន័យជាប្រាក់នេះមិនលើសពី ១លានរៀល[59]។

តុលាការ ក៏អាចសាកសួរសាក្សីនៅខាងក្រៅតុលាការបានដែរ ហើយសាក្សីត្រូវធ្វើសម្បថមុននឹងនិយាយទៅកាន់តុលាការ។ ក្នុងករណីដែលសាក្សីធ្វើសម្បថរួចហើយ ហើយបានផ្តល់សក្ខីកម្មក្លែងក្លាយ នឹងត្រូវផ្តន្ទាទោសនៅពេលតុលាការរកឃើញថាបានផ្តល់សក្ខីកម្មក្លែងក្លាយ[60]។

- ភស្តុតាងភាគី

តុលាការអាចធ្វើការសាកសួរភាគីបាន ហើយតុលាការអាចឱ្យភាគីនោះធ្វើសម្បថមុននឹងនិយាយទៅកាន់តុលាការ ហើយប្រសិនបើភាគីដែលបានធ្វើសម្បថបានក្លែងបន្លំសេចក្តីថ្លែងការណ៍ តុលាការអាចពិន័យជាប្រាក់។ ការពិន័យជាប្រាក់នេះ មិនលើសពី ២លានរៀល។

---

[58] មាត្រា១២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[59] មាត្រា១៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[60] មាត្រា១៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

នៅក្នុងការសាកសួរភាគី បើភាគីនោះមិនបានចូលខ្លួន ឬបានបដិសេធការធ្វើសម្បថ ឬបានបដិសេធការផ្តល់ចម្លើយដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការត្រឹមត្រូវ[61]។

ក្នុងករណីដែលតុលាការយល់ឃើញថា ចាំបាច់តុលាការអាចធ្វើការសាកសួរភាគីនៅព្រមពេលគ្នាជាមួយការសាកសួរភាគីម្ខាងទៀត និងជាមួយសាក្សីក្នុងពេលដំណាលគ្នាក៏បាន។

- ភស្តុតាងកោសលវិច័យ

នៅក្នុងដំណើរការនៃការស៊ើបអង្កេត តុលាការអាចបង្គាប់ឱ្យមានការធ្វើកោសលវិច័យតាមពាក្យសុំរបស់ភាគីបាន។

ក្នុងការធ្វើកោសលវិច័យ តុលាការជាអ្នកចាត់តាំងអ្នកជំនាញសម្រាប់ធ្វើកោសលវិច័យ ដូចជាជនដែលមានចំណេះវិជ្ជា និងបទពិសោធន៍ចាំបាច់ក្នុងការធ្វើកោសលវិច័យ។ ភាគីម្ខាងទៀតក៏មានសិទ្ធិប្តឹងបដិសេធអ្នកធ្វើកោសលវិច័យបានដែរ នៅមុនពេលដែលអ្នកធ្វើកោសលវិច័យបានធ្វើសេចក្តីសន្និដ្ឋាន ប្រសិនបើភាគីមានភស្តុតាងថា ធ្វើឱ្យរារាំងដល់សច្ចភាពចេញពីកោសលវិច័យ[62]។

- ភស្តុតាងឯកសារ

ភាគីអាចស្នើសុំទៅតុលាការ ដើម្បីធ្វើការពិនិត្យភស្តុតាងឯកសារនានាបាន ឬស្នើសុំទៅតុលាការដើម្បីបង្គាប់ឱ្យអ្នកមានឯកសារផ្តល់នូវឯកសារដែលខ្លួនមាន។ ក្នុងករណីចាំបាច់ តុលាការអាចឃាត់ទុកឯកសារដែលផ្ញើរមកនោះបាន។

ម្ចាស់ឯកសារ ពុំអាចបដិសេធនូវការផ្តល់ឯកសារដែលបានស្នើសុំដោយតុលាការបានទេ។ ក្នុងករណីដែលភាគីដែលជាម្ចាស់ឯកសារ មិនព្រមផ្តល់ឯកសារតាមការទាមទារទេ តុលាការអាចសន្និដ្ឋានថា សេចក្តីអះអាងរបស់ភាគីម្ខាងទៀតចំពោះឯកសារនោះជាការពិត ហើយចំពោះតតិយជនដែលជាម្ចាស់ឯកសារមិនព្រមផ្តល់ឯកសារតាមការទាមទាររបស់តុលាការ គឺតុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២លានរៀល[63]។

ដូចនេះក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលផ្ទាល់មាត់ហើយ បើយល់ឃើញថា ត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថ្មីម្តងទៀតបានដោយដីកាសម្រេច។ តុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗធ្វើការទាញហេតុផលចុងក្រោយបាន មុនពេលបញ្ឈប់ការទាញហេតុផលដោយផ្ទាល់មាត់។

[61] មាត្រា១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[62] មាត្រា១៩៣ ,១៩៤ និង ១៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[63] មាត្រា ១៥៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

## ៣.៣. ការសម្រេចសេចក្តី

ក្រោយពេលតុលាការបានបញ្ចប់ការស៊ើបអង្កេតរួចមក ត្រូវធ្វើការវិនិច្ឆ័យដល់អង្គសេចក្តី ដោយតុលាការត្រូវចេញសាលក្រម។ សាលក្រមគឺជាសេចក្តីសម្រេចសេចក្តី ដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់បានកំណត់[64]។ ផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ តាមរយៈសាលក្រមនេះ តុលាការកំណត់ថា តើចំណងអាពាហ៍ពិពាហ៍ត្រូវរំលាយ ឬបន្ត។

### ៣.៣.១ ខ្លឹមសារនៃសាលក្រម

ការសម្រេចសេចក្តីរបស់តុលាការនៅក្នុងរឿងក្តីនៃបណ្តឹងរដ្ឋប្បវេណីទូទៅ ខុសគ្នាពីការសម្រេចសេចក្តីនៅក្នុងរឿងក្តីនៃបណ្តឹងដែលទាក់ទងនឹងការលែងលះគ្នា។ ការសម្រេចសេចក្តីនៅក្នុងសាលក្រម ឬសាលដីការបស់តុលាការនៅក្នុងរឿងក្តីនៃបណ្តឹងរដ្ឋប្បវេណីទូទៅ តុលាការត្រូវសម្រេចតាមការទាមទារទាំងអស់ដែលភាគីបានសុំ ប៉ុន្តែតុលាការមិនអាចសម្រេចចំណុចណាមួយដែលភាគីមិនបានសុំឡើយ[65]។ ការនេះមិនមែនមានន័យថា ភាគីចង់ទាមទារអ្វីមួយក្នុងតម្លៃណាដែលភាគីចង់បាន ហើយតុលាការត្រូវតែសម្រេចឱ្យតាមការចង់បាននោះទេ។ ប៉ុន្តែនៅក្នុងករណីរឿងក្តីនៃបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងអាពាហ៍ពិពាហ៍ ច្បាប់បានផ្តល់សិទ្ធិឱ្យតុលាការសម្រេចសេចក្តីត្រង់ចំណុចណាដែលភាគីមិនបានស្នើសុំដោយឆន្ទានុសិទ្ធិបាន ប្រសិនបើចៅក្រមយល់ឃើញថាចាំបាច់ និងមានផលប្រយោជន៍ដល់ភាគី[66]។ ក្នុងករណីពិសេសនៃបណ្តឹងស្តីពីទំនាក់ទំនងអាពាហ៍ពិពាហ៍ប្រសិនបើតុលាការចេញសាលក្រម ឬសាលដីកាដែលទទួលស្គាល់ការទាមទាររបស់ដើមចោទ នៅក្នុងបណ្តឹងទាមទារលុបចោលនូវចំណងអាពាហ៍ពិពាហ៍ ឬលែងលះគ្នា តុលាការអាចធ្វើការសម្រេចសេចក្តី អំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិហើយបើមានពាក្យសុំរបស់ភាគីតុលាការអាចសម្រេចសេចក្តីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ។

សាលក្រមអាចសម្រេចដោះស្រាយផងដែរ ចំពោះបញ្ហាអាហារកិច្ច បញ្ហាបីបាច់រក្សាកូន បញ្ហាផ្គត់ផ្គង់កូន និងការបង្គាប់ឱ្យភាគីប្រគល់កូន ឬការផ្តល់តាវកាលិកផ្សេងៗទៀត។

[64] មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[65] មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[66] មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ ២០១០

នៅពេលដែលតុលាការធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ឬការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន តុលាការក៏ត្រូវថ្លឹងថ្លែងយោបល់របស់កូនដោយគិតពិចារណាអំពីអាយុរបស់កូន និងភាពចាស់ទុំរបស់កូននោះ។

ចំពោះករណីយកិច្ចដែលភាគីណាមួយត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តី តុលាការត្រូវសម្រេចដោយខ្លួនឯងទោះបីភាគីមិនបានសុំក៏ដោយ។

### ៣.៣.២ ការសម្រេចមិនឱ្យលែងលះគ្នា

ទោះបីមានមូលហេតុគ្រប់គ្រាន់តាមពាក្យបណ្តឹង សម្រាប់ការសម្រេចសេចក្តីឱ្យលែងលះគ្នាក៏ដោយ ប្រសិនបើការសម្រេចឱ្យលែងលះគ្នានោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនជួបការក្រលំបាកខ្លាំង ឬមានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះដោយឆន្ទានុសិទ្ធិដោយពិចារណាទៅលើស្ថានភាពទាំងឡាយនោះបាន។ មូល-ហេតុផ្សេងទៀត តុលាការក៏អាចច្រានចោលការទាមទារលែងលះគ្នាបានដែរ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះដោយឆន្ទានុសិទ្ធិបាន[67]។

### ៣.៣.៣ ការចូលជាស្ថាពររបស់សាលក្រម

ជាគោលការណ៍សាលក្រមរបស់តុលាការនឹងមានអានុភាពបាន លុះត្រាតែសាលក្រមនោះត្រូវបានប្រកាសជាផ្លូវការ និងជាសាធារណៈដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រម ជាអ្នកអានសេចក្តីសម្រេចបញ្ចប់។ ការប្រកាសសាលក្រមអាចធ្វើទៅបានទោះបីជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ[68]។

តាមវិធានទូទៅតុលាការត្រូវប្រកាសសាលក្រមនៅក្នុងរយពេល១ខែ ដោយគិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់។ ប៉ុន្តែចំពោះរឿងក្តីដែលមានភាពស្មុគស្មាញខ្លាំង ឬ ករណីមានកាលៈទេសៈពិសេសផ្សេងទៀត តុលាការអាចទុករយៈពេលសម្រាប់ការប្រកាសសាលក្រមយូរជាងនេះបាន[69]។ ច្បាប់មិនបានកំណត់ថា រឿងក្តីអ្វីខ្លះជារឿងក្តីស្មុគស្មាញ ហើយកាលៈទេសៈណាខ្លះជាកាលៈទេសៈពិសេស ដែលតុលាការអាចប្រើរយៈពេលយូរដើម្បីពន្យាការ

[67] មាត្រា៩៧៨ កថាខណ្ឌទី២ ទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[68] មាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[69] មាត្រា ១៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

ប្រកាសសាលក្រមនោះទេ។ ប្រការនេះធ្វើឱ្យភាគីមានការស្មុគស្មាញ និងមានការសង្ស័យលើតុលាការក៏មាន។

លិខិតសាលក្រមត្រូវបញ្ជូនទៅឱ្យភាគីក្នុងអំឡុងពេល២សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលតុលាការបានប្រកាសសាលក្រមនោះ[70]។

សាលក្រមរបស់តុលាការ អាចក្លាយទៅជាសាលក្រមស្ថាពរបានលុះត្រាតែបានកន្លងផុតអំឡុងពេលដែលច្បាប់អនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ ឬផុតរយៈពេលសម្រាប់បណ្តឹងទាស់ហើយពុំមានភាគីណាមួយប្តឹងឧទ្ធរណ៍ ឬប្តឹងទាស់ទេ។ ការចូលជាស្ថាពរនៃសាលក្រមត្រូវបានផ្អាក ក្នុងករណីដែលភាគីធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬពាក្យបណ្តឹងទាស់ ហើយនីតិវិធីរឿងក្តីលែងលះនឹងត្រូវដំណើរការបន្តទៀត។ ផ្ទុយទៅវិញ បើគ្មានការប្តឹងផ្តល់ដូចបានលើកឡើងខាងដើមទេ ហើយអំឡុងពេលដែលអនុញ្ញាតឱ្យប្តឹងក៏ត្រូវបានផុតកាលកំណត់ នោះសាលក្រមនឹងចូលជាស្ថាពរ ពោលគឺអានុភាពនៃអាជ្ញាអស់ជំនុំត្រូវបានកើតឡើង[71]។

អាជ្ញាអស់ជំនុំ មានន័យថានៅពេលដែលសាលក្រមចូលជាស្ថាពរហើយភាគីលែងលះមិនអាចលើកឡើងនូវទឡ្ហីករណ៍នានា មកប្តឹងសុំបន្តនីតិវិធីបានទៀតទេ ព្រោះតុលាការបានជំនុំជម្រះចប់សព្វគ្រប់ហើយ។ ម្យ៉ាងវិញទៀត តុលាការក៏អស់ភារៈកិច្ចក្នុងការដោះស្រាយរឿងក្តីនោះទៀតដែរ ពោលគឺសាលក្រមស្ថាពរនោះ ត្រូវបានយកមកប្រើប្រាស់ជាផ្លូវការ និងដោយស្របច្បាប់។

## ៣.៤ អានុភាពនៃការលែងលះដោយគ្មានការព្រមព្រៀង

### ៣.៤.១ អានុភាពចំពោះទ្រព្យសម្បត្តិ និងភាតព្វកិច្ច

#### ៣.៤.១.១ អានុភាពចំពោះទ្រព្យសម្បត្តិ

**ក. ទ្រព្យសម្បត្តិអកម្ម** (**បំណុល**)

- ❖ បំណុលផ្ទាល់ខ្លួន

ប្តីប្រពន្ធដែលស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ នៅពេលលែងលះ ទោះបីជាច្បាប់បានចែងថាប្តីប្រពន្ធមានការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះបំណុលក៏ដោយ ប៉ុន្តែសកម្មភាពមួយចំនួនមិនចាត់ចូលជាសកម្មភាពបំណុលរួមរបស់គ្រួសារឡើយដូចជា ការប្រព្រឹត្តល្បែងស៊ីសង ផឹកស្រា...ជាដើម ហើយត្រូវបានជំពាក់បំណុលគេ ទោះជាបំណុលនោះមាននៅមុន ឬក្រោយការរៀប

[70] មាត្រា ១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[71] មាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

អាពាហ៍ពិពាហ៍ក៏ដោយ សកម្មភាពទាំងនោះមិនចាត់ចូលជាបំណុលរួមរបស់គ្រួសារឡើយគឺជាបំណុលផ្ទាល់ខ្លួនរបស់សហព័ទ្ធ។

និយាយជារួមមក បំណុលទាំងឡាយណាកើតឡើងដើម្បីផលប្រយោជន៍បុគ្គល នោះមិនមែនជាបំណុលរួមរបស់គ្រួសារឡើយ[72]។ ដូច្នេះនៅពេលលែងលះគ្នា បំណុលនោះត្រូវជាបន្ទុករបស់សហព័ទ្ធម្ខាងទៀតដែលបានជំពាក់បំណុលគេនោះ។

❖ បំណុលរួម

បំណុលរួម គឺជាបំណុលទាំងឡាយណាកើតឡើងដើម្បីផលប្រយោជន៍គ្រួសារ នោះមិនមែនជាបំណុលបុគ្គល ឬ បំណុលផ្ទាល់របស់សហព័ទ្ធឡើយ[73]។ ហេតុនេះបំណុលដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ក៏ចាត់ទុកជាទ្រព្យរួមរបស់សហព័ទ្ធ។ ហើយទ្រព្យរួមនោះហៅថាទ្រព្យអកម្ម ចំពោះការបែងចែកទ្រព្យអកម្ម ចៅក្រមត្រូវធ្វើការបែងចែកបំណុលជាពីរដោយឲ្យសហព័ទ្ធក្លាយជាកូនបំណុល និងធ្វើការចេញសងបំណុលរួមគ្នានេះជាការទទួលខុសត្រូវដោយសាមគ្គីភាពរវាងប្ដីប្រពន្ធចំពោះម្ចាស់បំណុល។ ដូច្នេះសរបញ្ជាក់ឲ្យឃើញថា តុលាការមិនអាចធ្វើការបែងចែកបំណុលបានទេ គឺវានាំឲ្យប៉ះពាល់ដល់កាតព្វកិច្ចសាមគ្គីរបស់សហព័ទ្ធ[74]។ ឧទាហរណ៍៖ A(ប្ដី)និងB(ប្រពន្ធ) បានខ្ចីលុយធានាគារ ចំនួន៣០០០ ដុល្លារដើម្បីព្យាបាលជម្ងឺរបស់កូន ក្នុងករណីនេះ A និង Bត្រូវទទួលខុសត្រូវដោយសាមគ្គីភាពពោលគឺ ទាំងAនិងBគឺជាកូនបំណុល ហើយម្ចាស់បំណុលអាចទាមទារពី A និង Bបាន ហេតុនេះក្រោយការលែងលះតុលាការមិនអាចសម្រេចបែងចែកបំណុលបានទេ វានាំឲ្យប៉ះពាល់ដល់កាតព្វកិច្ចសាមគ្គីរបស់សហព័ទ្ធ។

**ខ. ទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា**

នៅត្រង់ចំណុចនេះ ប្ដីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬក្រោយអាពាហ៍ពិពាហ៍បាន[75]។ បានសេចក្ដីថា ប្ដីប្រពន្ធ នៅមុន ឬក្រោយពេលរៀបអាពាហ៍ពាហ៍អាចបណ្ដើរគ្នាទៅចុះកិច្ចសន្យាទ្រព្យសម្បត្តិនៅក្រសួងយុត្តិធម៌ ដើម្បីងាយស្រួលសម្រាប់ប្ដីប្រពន្ធនៅក្នុងគ្រួសារទៅថ្ងៃមុខ។ ដូច្នេះនៅពេលលែងលះនឹងមានការបែងចែកទ្រព្យសម្បត្តិ ជាហេតុនាំឲ្យចៅក្រមមិនពិបាកឡើយក្នុងការសម្រេច ដោយអនុលោមទៅតាមការកិច្ចសន្យាទ្រព្យសម្បត្តិប្ដី

[72] សៀវភៅ នីតិបេតិកភណ្ឌ និងគ្រួសារ របស់សាស្ត្រាចារ្យ អ្នកស្រីវណ្ណធី ទំព័រទី៣៧ បោះពុម្ពលើកទី៣ ខែមករា ឆ្នាំ ២០១៨

[73] សៀវភៅ នីតិបេតិកភណ្ឌ និងគ្រួសារ របស់សាស្ត្រាចារ្យ អ្នកស្រីវណ្ណធី ទំព័រទី៣៧ បោះពុម្ពលើកទី៣ ខែមករា ឆ្នាំ ២០១៨

[74] មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[75] មាត្រា ៩៦៩ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ប្រពន្ធនោះ។ ផ្ទុយមកវិញ ប្រសិនបើប្តីប្រពន្ធនោះ មិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាទេនោះ តុលាការអាចអោយភាគីប្តីប្រពន្ធនោះពិភាក្សាគ្នាក្នុងការបែងចែកទ្រព្យបាន។ ប៉ុន្តែប្រសិនបើភាគីមិនអាចពិភាក្សាគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិបានទៀត តុលាការនឹងសម្រេចធ្វើការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធនោះ កំណត់ទៅតាមច្បាប់។

**គ. ទ្រព្យសម្បត្តិរបស់សហព័ទ្ធកំណត់ដោយច្បាប់**

ច្បាប់បានបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធជា ២ប្រភេទគឺ ៖

- ទ្រព្យសម្បត្តិដោយឡែក
- ទ្រព្យសម្បត្តិរួម

ក្នុងករណីសហព័ទ្ធមិនអាចសម្រេចលើការព្រមព្រៀងគ្នា ក្នុងការបែងចែកទ្រព្យសម្បត្តិទេ ច្បាប់បានផ្តល់អំណាចដល់តុលាការ ដើម្បីសម្រេចបែងចែកទ្រព្យសម្បត្តិនោះ ជំនួសការព្រមព្រៀងរបស់ភាគី។

មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី បានផ្តល់អំណាចដល់តុលាការដើម្បីសម្រេចបែងចែកទ្រព្យសម្បត្តិតាមវិធី ៣ យ៉ាងដូចតទៅ៖

**+ ទី១ សហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែក** : ទ្រព្យសម្បត្តិដោយឡែកមានដូចជា ៖

- ទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។
- ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
- ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែកសហព័ទ្ធ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។

**+ ទី២ មានសិទ្ធិទទួលយកពាក់កណ្តាលនៃទ្រព្យសម្បត្តិរួម** : បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក១ ភាគ ២ នៃទ្រព្យសម្បត្តិរួមដែលសហព័ទ្ធបានរកស៊ីជាមួយគ្នា។

**+ ទី៣ ការបែងចែកទ្រព្យសម្បត្តិរួមដោយករណីពិសេស** : ក្នុងករណីពិសេស និង មានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិត

ជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។ ការងារនៃគេហកិច្ចត្រូវចាត់ថាមានតម្លៃស្មើនឹងការងារក្រៅផ្ទះដែរ"[76]។

**៣.៤.១.២ អានុភាពលើកាតព្វកិច្ច**

**ក. ការបញ្ចប់កាតព្វកិច្ចរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅក្នុងចំណងអាពាហ៍ពិពាហ៍**

ជាទូទៅដើម្បីកសាងគ្រួសារមួយដោយមានសុភមង្គល សហព័ទ្ធទាំងសងខាងគប្បីមានករណីកិច្ចស្រឡាញ់គ្នា ករណីកិច្ចគោរពគ្នាទៅវិញទៅមក ករណីកិច្ចមើលថែរក្សាគ្នា ករណីយកិច្ចជួយគ្នាទៅវិញទៅមក ករណីយកិច្ចសហការគ្នា ប៉ុន្តែដោយសារអានុភាពនៃការលែងលះកាតព្វកិច្ចរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមកត្រូវបញ្ចប់[77] ។

**ខ. កាតព្វកិច្ចសងជំងឺចិត្តអាចកើតមាន**

សំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល ត្រូវបានទទួលស្គាល់នៅក្នុងករណីលែងលះ និងអាចទាមទារនៅក្នុងបណ្តឹងលែងលះបាន[78]។ ក្នុងករណីលែងលះ ភាគីដែលគ្មានកំហុសហើយត្រូវបានភាគីម្ខាងទៀតបំពាន ភាគីដែលទទួលរងនូវការបំពានអាចទាមទារសំណងនៃការខូចខាតបាន។ឧទាហរណ៍៖ Aប្តី បានប្រព្រឹត្តអំពើផិត បានជេរប្រមាថ និងវាយតប់ B បណ្តោយឲ្យ Bទទួលរងរបួសជាទម្ងន់ ដោយត្រូវចំណាយប្រាក់ថ្លៃព្យាបាលអស់ ១៥០០ ដុល្លារ ហើយ B ទទួលរងនូវសម្ពាធផ្លូវចិត្តយ៉ាងខ្លាំង ក្នុងករណីនេះ B អាចទាមទារនូវសំណងខូចខាតចំពោះ Aបានទាំងសំណងខូចខាតផ្នែកសម្ភារៈ និងផ្លូវចិត្ត។

**គ. កាតព្វកិច្ចបង់អាហារកិច្ច**

ការទាមទារអាហារកិច្ចក្នុងករណីលែងលះ ពុំមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែមានបញ្ញាត្តិនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ មាត្រា ៧៦ បានទទួលស្គាល់ការទាមទារអាហារកិច្ច ហើយបញ្ញាត្តិនេះ នៅមានអានុភាពអនុវត្តនៅឡើយ តាមរយៈមាត្រា ៧៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ ការទាមទារអាហារកិច្ចត្រូវបានទទួលស្គាល់ក្នុងករណី ភាគីគ្មានកំហុសហើយមានការខ្វះខាតនៅក្នុងជីវភាពរស់នៅ អាចទាមទារអាហារកិច្ចពីភាគីម្ខាងទៀតបាន។ ឧទាហរណ៍: លោក ក បានមានស្នេហាលួចលាក់ជាមួយ នារី គ អស់រយៈពេលជាង២ឆ្នាំរឿង

[76] មាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[77] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[78] មាត្រា ១១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០

នេះបានធ្វើអោយ នារី ខ ដែលជាប្រពន្ធបានដឹង និងខឹងយ៉ាងខ្លាំង ហើយបានដាក់ពាក្យបណ្តឹងទាមទារលែងលះ ប៉ុន្តែលោក ក ពុំមានមុខរបរអ្វី ហើយក៏ពុំមានទ្រព្យសម្បត្តិដោយឡែកដែរ ក្នុងករណីនេះនារី ខ ដែលជាប្រពន្ធ អាចទាមទារឱ្យលោក ក បង់អាហារកិច្ចមកឱ្យខ្លួន។

### ៣.៤.២. អានុភាពលើស្ថានភាពគ្រួសារ

#### ៣.៤.២.១ ការបញ្ចប់ទំនាក់ទំនងញាតិពន្ធ

ទំនាក់ទំនងញាតិពន្ធ គឺចង់សំដៅទៅលើទំនាក់ទំនងញាតិ(សាច់ថ្លៃ)ខាងប្តី និងខាងប្រពន្ធនោះ។ នៅមុនពេលចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធមិនទាន់រំលាយ ទំនាក់ទំនងញាតិពន្ធមានទំនាក់ទំនងនឹងគ្នាល្អ មានការប្រាស្រ័យទាក់ទងគ្នា ចេះយកអាសារគ្នាទៅវិញទៅមក មានភាពស្និទ្ធស្នាលជាមួយគ្នាជាធម្មតា ប៉ុន្តែដោយសារតែអានុភាពនៃការលែងលះធ្វើឲ្យទំនាក់ទំនងញាតិពន្ធនោះ ត្រូវបានបញ្ចប់[79]។

#### ៣.៤.២.២. ការបញ្ចប់ភាពជាសន្តតិជន

សហព័ទ្ធដែលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ នៅក្នុងក្រមរដ្ឋប្បវេណី បានទទួលស្គាល់ថាសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ទោះបីជាមាន ឬ គ្មានសន្តតិជនផ្សេងទៀតក៏ដោយ[80]។ប៉ុន្តែ អ្វីៗទាំងអស់នេះនឹងបញ្ចប់ដោយអានុភាពនៃការលែងលះគ្នា។

#### ៣.៤.២.៣ នាមត្រកូលអាចត្រូវបានបញ្ចប់ដោយការលែងលះ

ប្តី ឬប្រពន្ធ ដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន[81]។

#### ៣.៤.២.៤ អ្នកមានអំណាចមេបា

នៅក្រោយការលែងលះ តុលាការនឹងសម្រេចអំពីអំណាចមេបាទៅលើកូនឲ្យភាគីណាម្ខាងជាអ្នកមានអំណាចមេបា អាចជាឪពុក ឬម្តាយ។ ការប្រគល់អំណាចមេបា គឺជាការប្រគល់សិទ្ធិគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា អប់រំកូន ទៅភាគីណាមួយក្រោយពីគូភាគីបានលែងលះគ្នា។

ក្នុងករណីឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្ខាងជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ។ ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នានៅមុនកំណើតកូន ម្តាយជាអ្នកមានអំណាចមេបាលើកូនដែលកើតមកនោះ។ ប៉ុន្តែនៅក្រោយ

---

[79] មាត្រា ៩៨១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[80] មាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[81] មាត្រា ៩៨១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

កំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន។

បើការពិភាក្សាខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ[82]។ ប៉ុន្តែប្រសិនបើកូននោះ អាចយល់ដឹង ហើយមានវ័យសមល្មម អាចជ្រើសរើសឪពុក ឬម្តាយជាអ្នកមានអំណាចមេបាន ដោយខ្លួនឯងបាន។ ក្នុងករណីមួយទៀត ប្រសិនបើអ្នកមានអំណាចមេបារបស់កូនដោយការពិភាក្សា បានទទួលមរណភាព ឪពុក ឬម្តាយដែលមិនមានអំណាចមេបាបាន ត្រូវក្លាយជាអ្នកមានអំណាចមេបា[83]។

**៣.៤.២.៥ អានុភាពនៃអត្តាធីនភាពនៅតែមាន**

អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលបានអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ហើយអនីតិជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាព។ ប៉ុន្តែក្នុងករណីដែលប្តី ឬប្រពន្ធដែលជាអនីតិជនមានចំណងអាពាហ៍ពិពាហ៍ ក្នុងករណីមានការលែងលះ អានុភាពនៃអត្តាធីនភាពនៅតែមានដដែលពុំបានបញ្ចប់តាមអានុភាពនៃការលែងលះនោះទេ។[84]

ដូចនេះបន្ទាប់ពីបានសិក្សាជំពូកទី១ សញ្ញាណនៃការលែងលះ ជំពូកទី២ នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង និងជំពូកទី៣ នីតិវិធីនៃការលែងលះដោយការគ្មានព្រមព្រៀងខាងលើនេះរួចមក យើងអាចធ្វើសេចក្តីសន្និដ្ឋានជារួមមួយនៅចំណុចជាបន្តទៀត។

[82] មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[83] មាត្រា ១០៥១ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[84] មាត្រា ២១ មាត្រា២២ និងមាត្រា ៩៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយ និងបង្ហាញទាំងទិដ្ឋភាពច្បាប់ និងទិដ្ឋភាពជាក់ស្ដែង ព្រមទាំងនីតិវិធី ទៅតាមដំណាក់កាលនីមួយៗនៃការលែងលះរួចមក អាចធ្វើឱ្យយើងមានចំណេះដឹង និងយល់ពីការលែងលះនេះបានច្រើនជាងមុន។ ជីវិតអាពាហ៍ពិពាហ៍ គឺជាដំណាក់មួយដែលមនុស្សគ្រប់រូប ដែលរស់នៅក្នុងសង្គមតែងតែឆ្លងកាត់ តែទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែមានមូលហេតុផ្សេងៗ ដែលធ្វើឱ្យភាគីសហព័ទ្ធពុំអាចរួមរស់ជាមួយគ្នាបន្តទៀតបាននោះ ពួកគេអាចធ្វើការលែងលះគ្នាបាន ដើម្បីបញ្ចប់ទំនាក់ទំនងរវាងគ្នា នឹងអាចបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មីទៀតបាន។ ការលែងលះគ្នា គឺជាបញ្ហាមួយដែលសង្គមណាក៏ធ្លាប់ជួបប្រទះដែរ ប៉ុន្តែចំពោះអាពាហ៍ពិពាហ៍ដែលកើតឡើងតាមផ្លូវច្បាប់ ការផ្ដាច់ចំណងអាពាហ៍ពិពាហ៍នោះ ក៏ត្រូវធ្វើឡើងតាមច្បាប់ដែរ។ សូមបញ្ជាក់ថាភាគីអាចធ្វើការលែងលះបានតាមពីរវិធី គឺតាមការលែងលះដោយមានការព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង។ នីតិវិធីដែលមានចែងនៅក្នុងច្បាប់ទាំងពីរប្រភេទនេះ ផ្ដល់ជម្រើសឱ្យភាគីធ្វើការពិភាក្សាគ្នា និងសម្រេចអំពីទំនាក់ទំនងរបស់អ្នកទាំងពីរបាន។

ដោយការលែងលះដោយមានការព្រមព្រៀង គឺមានភាពងាយស្រួលមានភាពឆាប់រហ័ស នីតិវិធីមិនមានភាពស្មុគស្មាញ ដោយភាគីគ្រាន់តែដាក់ពាក្យសុំ និងបង់ពន្ធដាក់ពាក្យសុំលែងលះព្រមព្រៀងទៅតុលាការដែលមានសមត្ថកិច្ច ហើយបង់ពន្ធដាក់ពាក្យសុំចំនួនប្រាំពាន់រៀលតែប៉ុណ្ណោះ។ ចំណែកឯតុលាការវិញ ពិនិត្យ ឬអាចធ្វើការសាកសួរពីភាគី ឬជនផ្សេងទៀត ហើយយល់ឃើញថាការព្រមព្រៀងនោះត្រឹមត្រូវគ្មានការបង្ខិតបង្ខំពីភាគីណាមួយនោះទេ តុលាការនឹងធ្វើការចេញដីកាសម្រេចឱ្យលែងលះដោយការព្រមព្រៀងអោយភាគី។

ចំពោះការលែងលះដោយគ្មានការព្រមព្រៀងវិញ គឺមានការលំបាកសម្រាប់ភាគីពីព្រោះថាវាទាមទារឱ្យមានការឆ្លងកាត់ដំណាក់កាលនីតិវិធីវែងឆ្ងាយ និងមានភាពស្មុគស្មាញដែលពាក់ព័ន្ធជាមួយវិវាទរបស់សហព័ទ្ធក្នុងការផ្ដាច់សមគ្គសង្វាស ការបែងចែងទ្រព្យ កូន អាហារកាតព្វកិច្ច។ ជាការពិតបើប្រៀបធៀបជាមួយ នីតិវិធីនៃការលែងលះរបស់ប្រទេសដទៃ នីតិវិធីនេះ អាចមានលក្ខណៈសាំញ៉ាំ និងចំណាយពេលវេលាយូរ ប៉ុន្តែនេះជានីតិវិធីមួយដែលអាចកាត់បន្ថយចំនួននៃការលែងលះបានដែរ ព្រោះភាគីមានឱកាសទទួលបាននូវការអប់រំផ្លូវចិត្តពីអ្នកផ្សះផ្សារ។

ទោះបីជាយ៉ាងណាក៏ដោយ ការលែងលះ បានបន្សល់ទុកនូវផលវិបាកដល់គ្រួសារ និងកូនជាច្រើនបន្ទិចមែន ក៏ប៉ុន្តែការលែងលះអាចធ្វើអោយភាគីសហព័ទ្ធរួចផុតពីចំណងដែលរស់នៅជាមួយភាពមិនចុះសម្រុង ក៏ដូចជាការកាត់ផ្ដាច់នូវចំណងអាពាហ៍ពិពាហ៍ដែលមានតែគុណ

វិបត្តិ ដែលផ្ទុយទៅនឹងគោលបំណងអាពាហ៍ពិពាហ៍នឹងមិនអាចទៅមុខជាមួយគ្នាបាន ព្រោះបើនៅតែបន្តពិតជានាំមកនូវបញ្ហាគ្មានថ្ងៃបញ្ចប់ ហើយអាចឈានទៅដល់ការប្រើអំពើហិង្សា ដែលកាន់តែប៉ះពាល់ផ្លូវកាយ ផ្លូវចិត្ត ជាពិសេសជាគំរូមួយមិនល្អដល់កូន និងសង្គម ហើយសហព័ទ្ធអាចយកមូលហេតុនៃការលែងលះណាមួយ ដែលបានបញ្ញត្តិនៅក្នុងច្បាប់សារធាតុមកធ្វើជាសំអាងនៃការលែងលះបាន។ ដូច្នេះការលែងលះ ក៏ជាវិធីដ៏ល្អបំផុតសម្រាប់ភាគីរងគ្រោះ ដែលអាចឱ្យស្វែងរក និងទទួលបាននូវជីវិតថ្មីដែលមានន័យ និងភ្លឺស្វាងមួយក្នុងជីវិត ជាជាងទ្រាំនឹងបញ្ហាដែលញាំញីទាំងផ្លូវចិត្ត ផ្លូវកាយ។

សរុបសេចក្តីមក មុននឹងសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ គប្បីកូនកម្លោះ កូនក្រមុំ ស្វែងយល់ពីគ្នាឱ្យបានច្បាស់ ក្នុងន័យនេះ ច្បាស់សំដៅទៅលើការស្គាល់ពីគ្នាទៅវិញទៅមករវាងសាមីខ្លួនទាំងពីរ រួមទាំងបរិបទសង្គមគ្រួសារទាំងសងខាងផងដែរ ជៀសវាងការមិនអាចទទួលយកបានត្រង់ចំណុចណាមួយដែលជាហេតុនៃរឿងរ៉ាវ នាំឱ្យឈានទៅដល់ការលែងលះគ្នានៅពេលក្រោយវិញ។

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់តាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី ការលែងលះនៅកម្ពុជាបច្ចុប្បន្ន ដែលបានបង្ហាញខាងលើនេះរួចមក ដើម្បីរួមចំណែកឱ្យប្រព័ន្ធច្បាប់ និងវិស័យយុត្តិធម៌កាន់តែប្រសើរឡើង យើងខ្ញុំសូមផ្តល់ជាសំណូមពរ និងបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនមួយចំនួនដែលយល់ថាគួរធ្វើការកែលម្អឱ្យកាន់តែប្រសើរឡើង ដើម្បីជាផលប្រយោជន៍ទាំងអស់គ្នា៖

- ក្រសួងមហាផ្ទៃគួររៀបចំបណ្តុះបណ្តាលទៅដល់មន្ត្រីអត្រានុកូលដ្ឋាន ក៏ដូចជាណែនាំអោយអនុវត្តនីតិវិធីនៃអត្រានុកូលដ្ឋាន ដើម្បីពួកគាត់មានសមត្ថភាពពេញលេញក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។
- បញ្ហាច្បាប់ពាក់ព័ន្ធជាមួយច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ចំពោះការប្រើពាក្យពេចន៍មិនទាន់មានភាពច្បាស់លាស់ និង មិនទាន់មានសុពលភាពគតិយុត្តនៅឡើយ។ ឧទាហរណ៍ ៖ ជនដាក់ពាក្យសុំ ឬអ្នកដាក់ពាក្យសុំជាអាទិ៍ តើយើងត្រូវគួរប្រើមួយណា? ដូច្នេះគួរវិសោធនកម្ម ឬកែប្រែយកពាក្យណាមួយឱ្យមានការឯកភាពគ្នាងាយស្រួលក្នុងការសិក្សាក៏ដូចជាអនុវត្ត។
- ចំពោះមន្ត្រីអត្រានុកូលដ្ឋាន ឃុំ សង្កាត់ គួរតែបន្តពង្រឹងទៅលើការផ្សះផ្សាគូភាគីដែលចង់លែងលះគ្នានោះឱ្យមានការត្រូវរ៉ូវគ្នាវិញ។ ចំណែកឯដំណាក់កាលផ្សះផ្សានៅតុលាការវិញ តុលាការគួរតែរិះរកគ្រប់មធ្យោបាយដែលពាក់ព័ន្ធនឹងការផ្សះផ្សាលើគូភាគីដែលចង់ធ្វើការលែងលះ ដើម្បីអោយងាកមកប្តូរចិត្ត ឈប់ចង់ធ្វើការលែងលះហើយងាកមករស់នៅជាមួយគ្នាជាប្តីប្រពន្ធធម្មតាវិញ។
- ចំពោះប្តីប្រពន្ធ ដើម្បីកុំឱ្យមានការកើតឡើងនៃការលែងលះ និងដើម្បីឱ្យគ្រួសារមួយមានសុភមង្គល គឺលុះត្រាតែភាគីប្តីប្រពន្ធគួរពិចារណាអោយបានត្រឹមត្រូវ គួរតែរស់នៅដោយភាពយោគយល់គ្នា ប្តីត្រូវបំពេញកាតព្វកិច្ចជាប្តីល្អ ប្រពន្ធត្រូវបំពេញកាតព្វកិច្ចជាប្រពន្ធល្អ ត្រូវចេះសហការគ្នាសង្គ្រោះគ្នាទៅវិញទៅមកដូចដែលមានចែងនៅក្នុងច្បាប់ បំពេញឱ្យបានគ្រប់ជ្រុងជ្រោយគ្រួសារនឹងជួបសុខសុភមង្គល។

# ឯកសារយោង

## I. ច្បាប់

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

២. ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

៣.ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

៤.ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០

៥.ច្បាប់ស្តីពីនីតិវិធីបណ្តឹងពាក់ព័ន្ធនឹងឋានៈបុគ្គលឆ្នាំ ២០១០

៦.ច្បាប់អាពាហ៍ពិពាហ៍នឹងគ្រួសារ ឆ្នាំ១៩៨៩

៧.ច្បាប់ស្តីពីឯកពន្ធភាពចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៦

៨.ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥

៩. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១

១០.ប្រកាសរបស់ក្រសួងយុត្តិធម៌ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧

## II. វចនានុក្រម

១. វចនានុក្រមខ្មែរអង្គរដែលធ្វើការកែសម្រួលពីវចនានុក្រមសម្តេចសង្ឃរាជជួនណាត ទំព័រ ៧៣

២.វចនានុក្រមអង់គ្លេស Cambridge University Press 1995 Page 403

## III. សៀវភៅ

១. សៀវភៅសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

២. សៀវភៅសេចក្តីកំណត់មាត្រានីមួយៗនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

៣. សៀវភៅ នីតិបេតិកភណ្ឌ និងគ្រួសារ របស់សាស្ត្រាចារ្យ អ្នកស្រីវណ្ណធី បោះពុម្ពលើកទី ៣ ខែមករា ឆ្នាំ២០១៨

៤. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ និងភាគ២

៥.សៀវភៅសេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី

៦.សៀភៅ លោកស្រី ហ៊ុយ ច័ន្ទរស្មី ជាសិស្សក្រឡាបញ្ជីជំនាន់ទី ៥នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការឆ្នាំ ២០១៨

៧.សៀភៅ សាន់ ដារ៉ា ជាសិស្សក្រឡាបញ្ជីជំនាន់ទី៤ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ ២០១៨

IV. **គេហទំព័រ**


- http://salatraju.com/index.php/post?p=22
- https___khmer4eversite.files.wordpress.com_2016_06_project-of-law.pdf
- https___lorkremlaw.files.wordpress.com_2014_09_e19e80e19eb6e19e9ae19e9be19f82e19e84e19e9be19f871.pdf
- http://m.freshnewsasia.com/index.php/en/localnews/97443-2018-09-02-.03-33-22html

# ឧបសម្ព័ន្ធ

# អនុសាសន៍

# ការលែងលះ

# ដោយមានការព្រមព្រៀង

# ( គ្មានកូន និង ទ្រព្យ )

# ការលែងលះ
# ដោយមានគ្មានការ
# ព្រមព្រៀង
# ( មានកូន និង ទ្រព្យ )

# ជំពូកទី១
# សញ្ញាណនៃការលែងលះ

# ជំពូកទី២
# នីតិវិធីនៃការលៃលះ
# ដោយការព្រមព្រៀង

# ជំពូកទី៣
# នីតិវិធីនៃការលែងលះ
# ដោយគ្មានការព្រមព្រៀង

# កំណត់ហេតុសះជា
# នៅក្រុមប្រឹក្សាឃុំសង្កាត់

# ឯកសារយោង

# សេចក្តីសន្និដ្ឋាន

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី
# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

# សេចក្តីផ្តើម